# អ្នកនាំសារ
# The Messenger

ឆ្នាំគ្រួសារ ២០១៧-២០២០

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមីនា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១០៩




## វគ្គអប់រំពិសេស

- អធិដ្ឋាន
- តមអាហារ
- ចែកទាន

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# កូនខ្មែរមួយក្រុម យកពោះវៀនកង់ឡាន ច្នៃជាកាបូបលុយធ្វើឲ្យបរទេសភ្ញាក់ផ្អើល




ផ្តើមចេញពីការចង់ថែរក្សា និងកែច្នៃរបស់របរចាស់ៗអោយមានគុណភាពល្អឡើងវិញ ព្រមទាំងអាចលើកម្ពស់ជីវភាពបានសមរម្យផងនោះ យុវជនមួយក្រុមបានចាប់ផ្តើមប្រមូលគ្នា ធ្វើគម្រោងមួយឡើង ហើយអាចផ្តល់ការងារជូនប្រជាពលរដ្ឋបានមួយចំនួនធំ ទាំងផ្ទាល់ និងប្រយោល។

មានយុវជនជាច្រើននាក់ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន តែងលើកឡើងថា ឱ្យតែមានដើមរកស៊ី មិនចង់ធ្វើការឱ្យគេទេ ព្រោះមិនងាយក្លាយជាអ្នកមាននោះទេ។ ចំណែកអ្នកខ្លះនិយាយថា ធ្វើការឱ្យគេពីរបីឆ្នាំនឹងឈប់ធ្វើការងារ ហើយចង់ទៅរកស៊ីវិញ។ រីឯយុវជនមួយចំនួន គឺចាប់ផ្តើមប្រថុយដាក់ទុនរកស៊ីតែម្តង ដូចជាជំនួញផ្នែកភេសជ្ជៈ និងអាហារជាដើម។

កូនខ្មែរមួយក្រុមបានបង្កើតភាពភ្ញាក់ផ្អើល ដោយបានច្នៃពោះវៀនកង់ចាស់ៗស្ទើរតែបោះចោល មកធ្វើជាកាបូបលុយម៉ាក Kraftino ហើយកំពុងល្បីល្បាញនៅក្រៅប្រទេស។ បច្ចុប្បន្ន កាបូបលុយ Kraftino កំពុងវាយលុកទីផ្សារនៅ សហរដ្ឋអាមេរិក អង់គ្លេស កាណាដា នូវែលហ្សេឡង់ និងអូស្ត្រាលីជាដើម។

លោក ប៊ុន ណារ៉ាទីតូ សហស្ថាបនិកនៃសហគ្រាសសង្គម Kraftino មានទីតាំងស្ថិតនៅ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានប្រាប់ឲ្យដឹងថា៖ "ដើមឡើយមុននឹងចាប់ផ្តើមមុខរបរនេះ យើងបានប្រាប់មិត្តភក្តិ បងប្អូនអំពីគំនិតច្នៃប្រឌិតនេះ ពួកគេមិនមានការជឿជាក់ មិនមានជំនឿថាអាចធ្វើបានជោគជ័យនោះទេ។ ប៉ុន្តែ រូបខ្ញុំផ្ទាល់ និងក្រុមការងារជឿថាអាចធ្វើវាបាន ព្រោះយើងបានសិក្សាទីផ្សារច្បាស់លាស់ ក៏ដូចជា សមត្ថភាពការផលិតរបស់ផលិតករខ្មែរយើង"។

កាបូបលុយម៉ាក Kraftino បង្កើតឡើងដោយក្រុមយុវជនចំនួន ៤នាក់ នៅអំឡុងឆ្នាំ ២០១៤ ក្នុងគោលបំណងចូលរួមគាំពារបរិស្ថានផង និងជួយលើកស្ទួយជីវភាពប្រជាជន ជាពិសេសស្ត្រីមេម៉ាយ ជនពិការ អ្នកមានជីវភាពខ្វះខាត និងជនក្រីក្រ ដោយឲ្យពួកគាត់ធ្វើការងារនៅតាមផ្ទះ។

លោក ប៊ុន ណារ៉ាទីតូ បានបញ្ជាក់ថា ពួកគាត់ភាគច្រើនជាស្ត្រី ហើយការធ្វើការងារតាមផ្ទះរបស់ពួកគាត់គឺអាចជួយសម្រួលដល់ការមើលថែរក្សាកូន និងអាចរកចំណូលដោយមិនចាំបាច់ទៅណាឆ្ងាយពីផ្ទះ។ ជាមួយគ្នានេះដែរ មិនគ្រាន់តែពួកគាត់ធ្វើកាបូបនេះមកលក់ជូនសហគ្រាសសង្គម Kraftino នោះទេ តែពួកគាត់ក៏អាចទទួលការបញ្ជាទិញពីអ្នកផ្សេងទៀតដែរ។

លោកទីតូ ឲ្យដឹងអំពីផលិតផលម៉ាក Kraftino នោះថា ផលិតផលកាបូបនេះ គឺធ្វើពីពោះវៀនកង់ដែលជ្រើសរើសភាគច្រើនជាពោះវៀនកង់ចាស់ជាពិសេសប្រភេទពោះវៀនកង់ឡានធំៗ (ឡានកង់១០ឡើង) ដែលពោះវៀនរបស់វាមានលក្ខណៈស្វិតល្អ និងមានក្រឡាតាមសម្បកកង់ដែលធ្វើឲ្យរូបរាងកាបូបលុយនេះ មានភាពស្រស់ស្អាត រំលេចតាមរយៈក្រឡាកង់ទាំងនោះ។ ផ្តើមពីចំណុចសូន្យ លោក ប៊ុន ណារ៉ាទីតូ បានឲ្យដឹងថា មកទល់នឹងពេលនេះ កាបូបលុយច្នៃពីពោះវៀនកង់កំពុងទទួលបានការចាប់អារម្មណ៍ជាច្រើន សម្រាប់ភ្ញៀវបរទេសដែលបានបញ្ជាទិញ។ ពួកគេបានសរសើរអំពីភាពរឹងមាំ និងភាពខុសប្លែកពីម៉ាកកាបូបផ្សេងៗ។

យ៉ាងណាក៏ដោយ លោក ទីតូ មានក្តីប្រាថ្នាដ៏ធំចង់បង្កើនការផលិត និងជំរុញការនាំចេញទាំងក្នុងស្រុក និងក្រៅប្រទេស ឲ្យពិភពលោកកាន់តែស្គាល់ផលិតផលរបស់ខ្មែរ។ ចំពោះតម្លៃវិញ កាបូបដៃ Kraftino លក់នៅទីផ្សារអន្តរជាតិតម្លៃ ២២.៩៩ ឯក្នុងស្រុកតម្លៃ ៦០,០០០ រៀល ស្មើនឹង ១៤.៩៩ ដុល្លារ ដែលស្វែងរកនៅតាមហាងធំៗ និងក៏មានដាក់លក់នៅលើបណ្តាញសង្គម ដែលប្រើគណនីហ្វេសបុក Kraftino។

បច្ចុប្បន្ននេះ សហគ្រាសសង្គម Kraftino មានបុគ្គលិកនិងកម្មករចំនួន១៥នាក់។ ដែលអាចផលិតបាន ៣០០ដល់៥០០ កាបូបក្នុងមួយខែ ក្នុងនោះមានកាបូបដៃបុរស និងស្ត្រី។ ហើយអនាគត លោកទីតូបានបញ្ជាក់ទៀតថា ក្រុមការងាររបស់គាត់កំពុងរកគំនិតច្នៃប្រឌិតជាកាបូបស្ពាយជាច្រើនម៉ូដផ្សេងៗទៀតដើម្បីបំពេញតម្រូវការទីផ្សារ៕

*ដោយ ផល ផលសុផានិត*

# តើអស់លោកអ្នកដឹងថាឧបករណ៍អេឡិចត្រូនិចដែលយើងកំពុងប្រើប្រាស់សព្វថ្ងៃនេះ មានផ្ទុកនូវវិទ្យុសកម្មដែរទេ ជាពិសេសគឺទូរសព្ទដៃដែលកំពុងមានការពេញនិយមប្រើប្រាស់ទាំងកុមារ និងមនុស្សពេញវ័យ ?

**តើអ្វីទៅជាវិទ្យុសកម្ម ?**

វិទ្យុសកម្ម គឺ ជារលកដែលសាយភាយចេញពីគ្រឿង Electronicsដូចជា ទូរសព្ទ កង្ហារ កុំព្យូទ័រ ទូរទស្សន៍ ម៉ាស៊ីនត្រជាក់ ឆ្នាំងដាំបាយអគ្គិសនី ទូទឹកកក ម៉ៃក្រូវ៉េវ និងគ្រឿងអេឡិចត្រូនិចផ្សេងៗទៀត រួមទាំងថាមពលអគ្គិសនីដើរដោយនុយក្លេអ៊ែរ ។

**តើវិទ្យុកម្មមាននៅកន្លែងណាខ្លះ ?**

បើនិយាយពីវិទ្យុសកម្ម គឺកើតមានឡើងគ្រប់ទីកន្លែងទាំងអស់នៅជុំវិញខ្លួនមនុស្ស ដោយសារការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចខាងលើនេះ ជាពិសេសកំណើននៃការប្រើប្រាស់ទូរសព្ទដៃបានកើនឡើងយ៉ាងច្រើនក្នុងបណ្ដាប្រជាជនក្នុងប្រទេសដែលកំពុងអភិវឌ្ឍ និងអភិវឌ្ឍនាពេលសព្វថ្ងៃនេះ ។

ធាតុវិទ្យុសកម្មអាចមាននៅស្ទើរតែគ្រប់ទីកន្លែង ក្នុងបរិយាកាស គ្រាន់តែមានក្នុងកម្រិតទាប ។ ជាទូទៅ មនុស្សម្នាក់ៗទទួលធាតុវិទ្យុសកម្ម ប្រមាណជា ២មីលីស៊ីវែរត៍ក្នុងមួយឆ្នាំ ។

**តើរលកវិទ្យុសកម្ម ធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្សយើងអ្វីខ្លះ ?**

ជំហានដំបូង របស់វិទ្យុសកម្មដែលប៉ះពាល់មកលើសុខភាពរបស់មនុស្សយើងគ្រប់រូបគឺធ្វើឱ្យយើងបាត់បង់ថាមពលនៅក្នុងខ្លួនពី ១០% ទៅ ៣០% ភ្លាមៗបន្ទាប់ពីយើងប៉ះពាល់ទៅ លើគ្រឿងអេឡិចត្រូនិចផ្សេងៗ នេះបើតាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្រ្តផ្នែកសុខភាពស្ទើរតែគ្រប់គ្នា។ ការជ្រាបចូលរបស់វិទ្យុសកម្មមកលើរាង្គកាយរបស់យើង គឺមិនបានធ្វើឱ្យយើងឈឺចាប់ភ្លាមៗនោះទេ ប៉ុន្តែវាបានជ្រាបចូល ទៅបំផ្លាញថាមពលរាង្គកាយ និងធ្វើឱ្យមានការប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទរបស់យើងដែលមានអាការៈស្ពឹកស្រពន់ ចុកដៃជើង ឈឺតាមសន្លាក់ ឈឺសាច់ដុំជាដើម។

ការថតកាំរស្មីអ៊ិច ( X-Ray ) ក៏បណ្ដាលឲ្យយើងទទួលធាតុវិទ្យុសកម្មដែរ ប៉ុន្តែទទួលក្នុងរយៈពេលខ្លី និងកម្រិតទាបដែលមិនបង្កគ្រោះថ្នាក់ដល់សុខភាពនោះឡើយ ។

អ្នកដែលទទួលរលកវិទ្យុសកម្ម ចាប់ពីកម្រិត ១ស៊ីវែរត៍ទៅ ( ស្មើនឹង១ពាន់មីលីស៊ីវែរត៍ ) ត្រូវចាត់ទុកជាអ្នកជំងឺវិទ្យុសកម្ម។ អ្នកជំងឺអាចត្រូវប្រឈមមុខនឹងជំងឺមហារីកខ្លាំង ប៉ុន្តែនៅអាចមានលទ្ធភាពព្យាបាលបាន។

អ្នកដែលទទួលសារធាតុវិទ្យុសកម្មចាប់ពី ៥ស៊ីវែរត៍ មានអត្រាស្លាប់ ៥០% បើសិនជាបានទទួលការព្យាបាលត្រឹមត្រូវ។ អត្រាស្លាប់អាចនឹងកើនឡើង រហូតដល់ ៩០% ឬ ១០០% ប្រសិនបើគ្មានការព្យាបាល។

អ្នកដែលទទួលសារធាតុវិទ្យុសកម្មចាប់ពី ៨ស៊ីវែរត៍ទៅ មានអត្រាស្លាប់ ១០០% មានន័យថា អ្នកជំងឺនឹងត្រូវស្លាប់ បើទោះជាមានការព្យាបាលត្រឹមត្រូវក៏ដោយ ។

ការប្រើប្រាស់ទូរសព្ទលោកអ្នកក៏ត្រូវប្រុងប្រយ័ត្នដែរ ព្រោះនៅពេលយើងនិយាយទូរស័ព្ទយើងយកវាមកផ្ទិបជាប់និងត្រចៀករបស់យើងក៏ដូចជាជាប់នឹងខួរក្បាលដូច្នេះដែរ ហើយកម្ដៅរបស់រលកវិទ្យុសកម្ម បានជ្រាបចូលទៅក្នុងខួរក្បាលបានយ៉ាងងាយ។ បន្តិចម្ដងៗ វាបានចម្អិនខួរក្បាលរបស់យើង ប្រសិនបើយើងនិយាយទូរសព្ទចាប់ពី១០នាទីឡើងទៅ។ លទ្ធផល គឺធ្វើឱ្យយើងឈឺក្បាល ក្ដៅត្រចៀក មានអារម្មណ៍ឆាប់មួរមៅ គេងមិនលក់ធ្វើឱ្យខ្សោយក្នុងការចងចាំស្ពឹកខួរក្បាល។ល។

ផលប៉ះពាល់បន្តិចម្ដងៗនេះហើយដែលវាធ្វើឱ្យមានបញ្ហាធ្ងន់ធ្ងរទៅថ្ងៃអនាគតដូចជាកើតមហារីកខួរក្បាល មហារីកគ្រាប់ឈាម ថាមពលរាង្គកាយចុះខ្សោយខ្សោយមេជីវិតបុរសរហូតដល់៣៥% ងាយឆ្លងរោគផ្សេងៗ ចំពោះស្ត្រីដែលមានផ្ទៃពោះធ្វើឱ្យការបង្កកំណើតខុសប្រក្រតីជាដើម ។

តាមរបាយការណ៍មួយដែលចេញដោយប្រទេសអាល្លឺម៉ង់ដែលបានសិក្សាលើទូរសព្ទដៃអំពីម៉ូដែលទូរសព្ទស្មាតហ្វូន កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ បានរកឃើញថា ទូរសព្ទមួយចំនួនមានវិទ្យុសកម្មច្រើនជាងគេ ដែលមានដូចជា៖ ONE-plus 5T, Hauwei mate 9, Nokia Lumia 630, Hauwei P9 Plus, Hauwei GX8, Hauwei P9 ជាដើម។ ទោះបីជាកន្លងមកធ្លាប់មានមតិលើកឡើងថាវិទ្យុសកម្មដែលសាយភាយចេញពីទូរសព្ទអាចបង្កផលប៉ះពាល់ដល់សុខភាព ប៉ុន្តែតាមរយៈលទ្ធផលថ្មីចុងក្រោយ នៃការសិក្សារយៈពេល ២ឆ្នាំរបស់រដ្ឋបាលចំណីអាហារ និងឱសថសហរដ្ឋអាមេរិក ( FDA ) បង្ហាញថាវិទ្យុសកម្មពីទូរសព្ទមិនផ្ដល់ប៉ះពាល់ដល់សុខភាពមនុស្សឡើយ ព្រោះវាមានកំរិតទាប ៕

*ដោយកែវ កញ្ញា*



ថតដោយ: វិទ្ធី

# សេវាកម្មទេសចរណ៍រីកចម្រើន កម្ពុជាកំណត់គោលដៅទាក់ទាញភ្ញៀវទេសចរអន្តរជាតិ១៥ លាននាក់


រូបភាពពីហ្វេសបុក ក្រសួងទេសចរណ៍

វិស័យទេសចរណ៍កម្ពុជាកំពុងតែរីកចម្រើន ខណៈដែលធនធាននិងសេវាកម្មសម្រាប់វិស័យនេះ ក៏កំពុងតែស្ថិតនៅក្នុងនិន្នាការមួយប្រកបដោយសុទិដ្ឋិនិយម និងវិជ្ជមានផងដែរ។

សេវាទេសចរណ៍នៅក្នុងប្រទេសកម្ពុជា រួមមានកន្លែងស្នាក់នៅ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត ក៏ដូចជាមគ្គុទ្ទេសក៍ទេសចរណ៍មានការកើនឡើងជាវិជ្ជមាន។ យោងតាមស្ថិតិដែលបានចេញផ្សាយនៅក្នុងព្រឹត្តិការណ៍ទេសចរណ៍ ដែលរៀបចំពីថ្ងៃទី២៧ ដល់២៨ ខែកុម្ភៈ គេបានឲ្យដឹងថា កាលពីឆ្នាំមុន កម្ពុជាសណ្ឋាគារមានចំនួន ៧៨១កន្លែង ផ្ទះសំណាក់ ២.២៥៥កន្លែង ភោជនីយដ្ឋានមាន ២.២៣៩កន្លែង មជ្ឈ-មណ្ឌលកម្សាន្តសម្រាប់មនុស្សពេញវ័យ មានចំនួន ៨៨១កន្លែង ទីភ្នាក់ងារទេសចរណ៍ចំនួន៦១៩ និងមគ្គុទ្ទេសក៍ចំនួន ៦.១២៣នាក់ និយាយ ១២ភាសា ខណៈដែលកាលពីនៅឆ្នាំ២០១៦ ប្រទេសកម្ពុជាមានសណ្ឋាគារតែ ៦៤៧កន្លែង ផ្ទះសំណាក់ ១.៩៩៦កន្លែង ភោជនីយដ្ឋាន ១.៨៤៤កន្លែង និងមជ្ឈមណ្ឌលកម្សាន្តមនុស្សពេញវ័យ ៦៨៨ កន្លែង។ កាលពីឆ្នាំ ២០១៧ កន្លងទៅ កម្ពុជាអាចទាក់ទាញភ្ញៀវទេសចរបរទេសប្រហែល ៥,៦ លាននាក់ មកលេងប្រទេសកម្ពុជា ដោយកើនឡើង ១១,៨ ភាគរយ និងទាញចំណូលចំនួន ៣,៦៣ ពាន់លានដុល្លារកើនឡើង ១៣,៣ ភាគរយ។ ដើម្បីជំរុញឲ្យវិស័យទេសចរណ៍កាន់តែសកម្ម និងបន្តរួមចំណែកដល់សេដ្ឋកិច្ចជាតិ ប្រមុខរាជរដ្ឋាភិបាលផ្តល់អនុសាសន៍គន្លឹះចំនួនបី។

សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីកម្ពុជាបានផ្តល់នូវអនុសាសន៍គន្លឹះថា ខណៈដែលកម្ពុជាកំពុងមានឧត្តមភាពប្រកួតប្រជែងខ្ពស់ខាងវិស័យទេសចរណ៍ កម្ពុជា យើងត្រូវតែចងចាំថាសុខសន្តិភាពស្ថិរភាពនយោបាយនិងសុវត្ថិភាពសង្គមគឺជាគន្លឹះដ៏រឹងមាំនៃការអភិវឌ្ឍន៍ទេសចរណ៍ឲ្យរីកចម្រើនដូចសព្វថ្ងៃនេះ។ ក្នុងស្មារតីនេះរាជរដ្ឋាភិបាលប្តេជ្ញាចិត្តប្រឆាំងរាល់ការប៉ុនប៉ងណាមួយដែលធ្វើឲ្យប៉ះពាល់សុខសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គមនៅកម្ពុជាបើទោះបីត្រូវធ្វើក្នុងតម្លៃណាក៏ដោយ ពីព្រោះថាមានសុខសន្តិភាពទើបមានការអភិវឌ្ឍ។ ដូច្នេះចំពោះមុខយើងត្រូវខិតខំរួមគ្នាថែរក្សាបាននូវសុខសន្តិភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមឲ្យបានរឹងមាំយូរអង្វែងសម្រាប់ផ្តល់ផ្លែផ្កាដល់ប្រជាជន និងសង្គមជាតិ។

សម្តេចតេជោ បានផ្តល់អនុសាសន៍ទីពីរថា ត្រូវកំណត់ឆ្នាំ ២០១៨គឺជាឆ្នាំសម្រាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព ដើម្បីឆ្ពោះទៅសេដ្ឋកិច្ចបៃតងនៅកម្ពុជា។ ព្រះរាជាណាចក្រកម្ពុជាពិតជាមានសំណាងណាស់ដែលដូនតាបានកសាងប្រាសាទអង្គរដែលបានក្លាយជាសម្បត្តិបេតិកភណ្ឌមនុស្សជាតិ និងជាបេតិកភណ្ឌពិភពលោក ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុកដែលមាន តម្លៃវប្បធម៌ជាសាកល និងពុំអាចកាត់ថ្លៃបានរបស់មនុស្សជាតិ និងប្រាង្គប្រាសាទជាច្រើនទៀតនៅទូទាំងប្រទេសបានលើកស្ទួយតម្លៃមរតកដូនតាទាំងអរូបិយ រូបិយ និងសម្បត្តិធម្មជាតិដែលកម្ពុជាមាន។ យើងខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមនានាដូចជា ១.ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ទេសចរណ៍សំខាន់ៗសមស្របតាមបទដ្ឋានមួយច្បាស់លាស់។ ២.ការសាងសង់នៅក្នុងតំបន់ឧទ្យានជាតិ និងបេតិកភណ្ឌវប្បធម៌ត្រូវអនុវត្តឲ្យបានសមស្រប នឹងរចនាបថខ្មែរនិងតម្លៃនៃសម្បត្តិវប្បធម៌ខ្មែរ។ ៣.ការសាងសង់សំណង់រឹងតាមបណ្តោយឆ្នេរ លើចំណីឆ្នេរ សំណល់រឹងនិងរាវត្រូវអនុវត្តវិធានការច្បាប់ និងបទដ្ឋានបរិស្ថាន។ ៤.ការគ្រប់គ្រងឲ្យបានម៉ត់ចត់លើការប្រើប្រាស់ទឹកបញ្ហាថាមពលនិងសារធាតុមួយចំនួនដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ និង៥.ការគ្រប់គ្រងលើធ្វើការងារទាក់ទងវិស័យទេសចរណ៍ពិសេសការគ្រប់គ្រងសកម្មភាពទេសចរមួយចំនួនដែលវានឹងគោរពតាមបទដ្ឋានការងារ និងការទទួលខុសត្រូវ។

សម្តេចតេជោ ហ៊ុន សែន ក៏បានបន្តសង្កត់ធ្ងន់ដោយបន្ថែម អនុសាសន៍ ទី៣ ដោយបន្តនាំគ្នាទាក់ទាញភ្ញៀវទេសចរណ៍ឲ្យកាន់តែច្រើន និងស្រូបយកភ្ញៀវទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "ខ្ញុំពិតជាមានសុទិដ្ឋិនិយមថាភ្ញៀវទេសចរណ៍កម្ពុជានឹងមានកំណើនកាន់តែច្រើនថែមទៀតនៅពេលដែលមានការវិនិយោគបន្ថែមលើផលិតផលទេសចរណ៍ និងការទុកចិត្តតាមផ្លូវការតភ្ជាប់ផ្លូវគោកផ្លូវទឹកនិងផ្លូវដែកកាន់តែមានភាពប្រទាក់ក្រឡាច្រើនថែមទៀត។ ទោះបីយ៉ាងណាដើម្បីចូលរួមចំណែកសម្រេចបានចក្ខុវិស័យក្នុងការទទួលបានភ្ញៀវទេសចរអន្តរជាតិ១៥លាននាក់នៅឆ្នាំ២០៣០ យើងត្រូវគិតគូរយ៉ាងខ្លាំងពីការជំរុញការតភ្ជាប់ជាពិសេសតាមផ្លូវអាកាសការបង្កើតកញ្ចប់ទស្សនកិច្ចទេសចរណ៍....។

សម្តេចតេជោ ហ៊ុន សែន ក៏បានលើកទឹកចិត្តឲ្យកម្ពុជាបន្តទាក់ទាញភ្ញៀវទេសចរជនជាតិចិនបន្ថែមទៀត។

សម្តេចតេជោ ហ៊ុន សែន បានជំរុញឲ្យរួមគ្នាត្រៀមអនុវត្តសៀវភៅស្តីអំពីការត្រៀមទទួលទេសចរណ៍ចិនខណៈអង្គការទេសចរណ៍ពិភពលោកបង្ហាញថាលំហូរភ្ញៀវទេសចរណ៍ចិននឹងកាន់តែមានកំណើនយ៉ាងគំហុកនៅលើពិភពលោកក៏ដូចជានៅក្នុងតំបន់ ព្រមទាំងការរៀបចំវេទិកាកំពូលទេសចរណ៍កម្ពុជាចិនប្រចាំឆ្នាំដើម្បីស្វែងរកឱកាសល្អៗសម្រាប់ការធ្វើពិពិធកម្ម និងការពង្រីកវិសាលភាពទេសចរណ៍កម្ពុជា។

កាលពីឆ្នាំ២០១៧កន្លងទៅនេះ កម្ពុជាសម្រេចបានអត្រាកំណើនសេដ្ឋកិច្ច៧%។ ក្នុងនោះវិស័យទេសចរណ៍បានរួមចំណែកប្រមាណ១៣ភាគរយនៃផលិតផលក្នុងស្រុកសរុបនិង បានចូលរួមបង្កើតឱកាសការងារដល់ប្រជាជនកម្ពុជារាប់សែននាក់ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ លើសពីនេះទៀតយើងសង្ឃឹមថានៅឆ្នាំ២០២០កម្ពុជារំពឹងថានឹងទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧លាននាក់ និងនាំមកនូវចំណូលចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិប្រមាណ ៥ពាន់លានដុល្លារអាមេរិក។ បង្កើតនូវឱកាសការងារដល់ប្រជាជនកម្ពុជាដោយផ្ទាល់ប្រមាណ១លាននាក់។ ឆ្នាំ២០៣០កម្ពុជារំពឹងថា និងទទួលភ្ញៀវទេសចរប្រមាណ១៥លាននាក់និងនាំមកនូវចំណូលចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិប្រមាណ១០ប៊ុលានដុល្លារអាមេរិកបង្កើតការងារប្រមាណ២លាននាក់ដលែជាការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា៕

*ដោយ អរិយបុត្រ*

# អាណាព្យាបាល៖ ការងារសិល្បៈសប្បាយនិងហ៊ឺហាទើបយុវជននិងកុមារចូលចិត្ត

ខណៈដែលកម្មវិធីសិល្បៈត្រូវបានផ្សព្វផ្សាយយ៉ាងផុលផុសនៅក្នុងសង្គមតាមគ្រប់មធ្យោបាយ គួបផ្សំនិងភាពហ៊ឺហាហើយសប្បាយផងនោះ នាំឲ្យចំណាប់អារម្មណ៍របស់យុវជននិងយុវនារីទៅលើការងារសិល្បៈនេះ កាន់តែបាក់។ នេះបើតាមសំដីអាណាព្យាបាលមួយចំនួន បានចូលរួមបញ្ចេញយោបល់ ទាក់ទងនឹងការផ្សព្វផ្សាយសិល្បៈសម្បូណ៍បែបពេក ។

លោក រិន ចំណាន ជាអាណាព្យាបាលរបស់យុវជនវ័យ១៦ឆ្នាំម្នាក់ និងយុវនារីវ័យ ១៤ឆ្នាំម្នាក់បានបញ្ចេញយោបល់ថា ការផ្សព្វផ្សាយ និងលើកទឹកចិត្តអំពីសិល្បៈនៅតាមប្រព័ន្ធផ្សព្វផ្សាយគឺដូចជា ហួសបន្តិច ដែលនាំឲ្យកូនៗរបស់លោក ក៏មានទំនោរបាក់ទៅរកការងារនេះដែរ។

លោកបានថ្លែងបញ្ជាក់ថា "កុំឲ្យតែឮអាដែងកម្មវិធីស្តារគេទេ គេកំពុងប្រឡងមានតារា ល្បីៗធ្វើអីJudge (មេប្រយោក) គឺពួកគេមើលអត់ដេកអត់ពួនទេ រហូតកាន់សៀវភៅបណ្តើរ បើកកម្មវិធីនេះ មើលបណ្តើរទៀត"។

តាមការរៀបរាប់របស់លោក ចំណាន កូនៗរបស់លោក ជាយុវជនដែលរៀនពូកែបង្គួរមួយ ប៉ុន្តែឥឡូវដូចជាមានអារម្មណ៍ថា ដូចជាធ្លាក់ចុះ ប៉ុន្តែលោកក៏មិនដាក់កំហុសទៅលើកម្មវិធីសិល្បៈនេះដែរ។

លោកបានចែករំលែកបទពិសោធន៍របស់លោកថា កូនៗរបស់លោកពីមុនមកដូចជាមិនសូវនិយមមើលទូរទស្សន៍ខ្មែរទេ ពោលគេមើលតែកម្មវិធីបរទេស ដូចជាឯកសារសត្វ ការស្រាវជ្រាវនេះ ការស្រាវជ្រាវនោះ ប៉ុន្តែមួយរយៈពេលកន្លងមកនេះ គឺពួកគេចូលចិត្តមើលកម្មវិធីទូរទស្សន៍ខ្មែរ ជាពិសេស គឺកម្មវិធីប្រឡងចម្រៀងស្តារទេ។ លោកបានចែករំលែកទៀតថា តាំងពីមើលកម្មវិធីនេះ ឃើញចំណង់ចំណូលចិត្ត និងទម្លាប់នៃការរស់នៅរបស់ពួកគេក៏មានការប្រែប្រួល ហើយអត្តចរិតក៏ដូចជាប្លែកបន្តិច ។

លោកបានរៀបរាប់ថា វាពិបាកនឹងរ៉ាយរ៉ាប់ណាស់ថា ពួកគេប្លែកយ៉ាងម៉េច ប៉ុន្តែនៅក្នុងនាមជាអាណាព្យាបាល លោកដឹងថា ពួកគេកំពុងតែមានការប្រែប្រួល។

លោកបានបញ្ជាក់ថា "ពីមុនម៉ោង ១០ ឬ១១យប់អី គឺពួកគេគេងហើយ ប៉ុន្តែឥឡូវជួនកាល ១២ពេលសួរទៅ គេថា កំពុងតាមដានកម្មវិធីចប់សិន។ ហើយពេលទំនេរ មិនដឹងជាស្តារទេ ឃើញពួកគេជជែកគ្នា ស៊ិះស៊ុះៗ តែអាកម្មវិធីនោះ"។

លោកចំណាន បានបន្តថា សង្ស័យតែពួកគេចាប់អាជីពនេះទេមើលទៅ បើមួយថ្ងៃៗគិតតែមើលពីអាកម្មវិធីទាំងនេះ ទាំងកូនប្រុស និងកូនស្រី។ លោកបានបន្តទៀតថា ទោះគ្មានកម្មវិធីទូរទស្សន៍ក៏ខ្ញុំសង្កេតឃើញពួកគេអង្គុយមើលតាមហ្វេសបុក តាមយូធូបថែមទៀត។

នេះគឺជាការចែករំលែកបទពិសោធន៍របស់លោក ចំណាន អំពីការប្រែប្រួលនៃឥរិយាបទរបស់កូនៗរបស់លោកបន្តិចបន្តួច ប៉ុន្តែ លោកស្រី ច័ន្ទ ផល្លិការ ជាស្ត្រីមេផ្ទះមួយរូប ក៏បានឲ្យដឹងថា កុមារីវ័យ ៦ ឆ្នាំមួយរូបរបស់លោកស្រី គឺកំពុងតែ លង់នឹងការរាំការច្រៀងតាមកម្មវិធីទូរទស្សន៍។

លោកស្រី ផល្លិការ បានឲ្យដឹងថា លោកស្រីមានបំណងចង់ឲ្យកូនរៀនធ្វើពេទ្យ ឬការងារណាសមរម្យ ប៉ុន្តែមើលទៅ មិនដឹងយ៉ាងម៉េចទេ បើឃើញតែរាំច្រៀងដាក់កញ្ជក់តែរហូត។ លោកស្រីបានរៀបរាប់ ទាំងសើចផងថា ប៉ាគេមិនចង់ឲ្យគេស្រលាញ់ចូលចិត្តអាការងារសិល្បៈអីហ្នឹងទេ ហើយចេះតែហាម កូនមិនឲ្យមើលទូរទស្សន៍ដែលមានកម្មវិធីអស់ហ្នឹង ប៉ុន្តែគាត់រវល់ ហើយលោកស្រីក៏រវល់។ មួយថ្ងៃៗ កូននៅតែជាមួយនឹងប្អូនជំទើរ ហើយគាត់ចូលចិត្តអាកម្មវិធីអស់ហ្នឹងអីចឹងក៏ចេះតែអីចឹងទៅ ។

លោកស្រី បានបញ្ជាក់ថា "ពីមុន ពេលសួរគេ (កូនស្រីលោកស្រី) គេឆ្លើយថា ចង់ធ្វើពេទ្យ តាមបំណង ប៉ាគេ តែតាំងពីទូរទស្សន៍ចូលខ្លួនមក ពេលប៉ាគេសួរថា ធំឡើងធ្វើអ្វី គេឆ្លើយថា តារាចម្រៀង"។

លោកស្រី បានបន្តទៀតថា ហេតុតែចង់ឲ្យកូនធំឡើងធ្វើពេទ្យ គាត់ខំទិញរបស់លេង រូបភាព ស្អីៗ ដែលនិយាយពីពេទ្យ ឲ្យកូនលេង កូនមើល តែមានទៅឈ្នះ អាកម្មវិធីទូរទស្សន៍អី ពីព្រោះវាសប្បាយ ស្លៀកពាក់ស្អាតៗ ហ៊ឺហារ ។

លោកស្រីបានបញ្ជាក់ថា "ប៉ាគេ ឥឡូវមាននិយាយអី បើតែម៉ាកៗហ្នឹង"។

លោក ជៀន ចេងវិរៈ ជាមន្ត្រីចូលនិវត្តន៍មួយរូប បានថ្លែងថា ជាទូទៅក្មេងតែឃើញការសប្បាយ ឃើញភាពហ៊ឺហាគេចង់ហើយ ប៉ុន្តែយើងជាអាណាព្យាបាលកុំប្រឆាំងជាមួយនឹងបំណងរបស់គេ កុំជំទាស់ នឹងអ្វីដែលគេចូលចិត្ត ប៉ុន្តែព្យាយាមនិយាយទាញចំណាប់ អារម្មណ៍គេដោយមានហេតុមានផល មានអំណះអំណាង ហើយព្យាយាមពន្យល់ ដោយត្រដាក់បំផុត ព្យាយាមផ្តល់ភាពកក់ក្តៅអប់រំ លើកទឹកចិត្តគេ។

លោក វិរៈ បានឲ្យដឹងថា លោកក៏ធ្លាប់ជួបរឿងរ៉ាវទាំងអស់នេះខ្លាំងដែរ កាលកូនៗគេនៅជំទើរ ដោយអាអន្ទិតមួយនោះគេចង់ទៅប្រឡងចម្រៀង។ "កាលនោះ ខ្ញុំឲ្យទៅ តែបានដាក់លក្ខខណ្ឌ ហើយ បានលើកទឹកចិត្ត និងអូសទាញគេបន្តិចម្តងៗ តែឥឡូវគេក្លាយជាវិស្វករហើយ"។

លោកបានបញ្ជាក់ថា " ក្មេងប្រឆាំងគេមិនបានទេ គឺវ៉ៃស្របតាមគេ ប៉ុន្តែត្រូវព្យាយាមទាញគេ កុំផុងផាំង ប្រយ័ត្នខូចកូន កែលែងឡើង"។

លោកបានបន្តថា ការងារសិល្បៈនេះល្បីតែពេលមានគេគាំទ្រទេ តែពេលអស់ល្បីមុខក៏គេមិនមើលផង។

ជុំវិញបញ្ហានេះ តាមការរៀបរាប់របស់លោកចំណាន លោកក៏បានឯកភាពនិងលោកវិរៈ ហើយអះអាងថា អាណាព្យាបាលនានា ភាគច្រើនក៏បានឯកភាពដែរ។ លោកចំណានបានបញ្ជាក់ថា "ក្មេង ប្រឆាំងមិនបានតែម្តង ទោះគេមានបទពិសោធន៍តិចជាងយើងមែន តែគេក៏មានហេតុផលរបស់គេដែរ"។

លោកបានបន្ថែមទៀតថា មិត្តភក្តិរបស់លោក ក៏មិនតិចទេ ដែលកំពុងតែប្រឈមនឹងបញ្ហាស្រដៀងគ្នានេះ ហើយក៏ចេះតែពិភាក្សាគ្នារឿងនេះជាមួយគ្នាជាហូរហែ ហើយនាំគ្នាព្យាយាមរកហេតុរកផល មកបង្វែរការចាប់អារម្មណ៍របស់ពួកគេ៕

*ដោយ អរិយបុត្រ*



ថតដោយ: លីហៀង

# កម្មករ និងកម្មការិនីថា មិនដឹងជាធ្វើអ្វីប្រសិនបើគ្មានរោងចក្រ និងការងារនៅទីក្រុង

កម្មករ និងកម្មការិនីរោងចក្រកាត់ដេរ ក៏ដូចជាកម្មករនៅក្នុងវិស័យនានា មិនសូវជាចាប់អារម្មណ៍នឹងស្ថានភាពនយោបាយនៅកម្ពុជាទេ ប៉ុន្តែពួកគេហាក់មានអារម្មណ៍មិនច្បាស់អំពីអនាគតរបស់ពួកគេ ប្រសិនបើគ្មានរោងចក្រ គ្មានសំណង់ គ្មានការងារនៅក្នុងទីក្រុងធ្វើ ដោយសារតែដីស្រែរបស់ពួកគេតិច ខ្លះថា លក់អស់ទៅទៀត។

អ្នកនាង ចេង សេងទៀង ជាកម្មការិនីរោងចក្រកាត់ដេរនៅម្តុំទទួលសង្កែ ដែលមកពីសុក្រទ្រាំង ខេត្តតាកែវ បានឲ្យដឹងថា អ្នកនាងបានមកធ្វើការនៅទីក្រុងភ្នំពេញនេះ អស់រយៈពេលជាង ១០ឆ្នាំហើយ ដោយមកតាំងពីអាយុ ១៦ឆ្នាំ ហើយឥឡូវនេះ អាយុ ៣៣ឆ្នាំហើយ ។

អ្នកនាងបានរៀបរាប់ថា អ្នកនាងមិនមែនមកធ្វើការនៅទីក្រុងនេះតែឯងនោះទេ ពោលគឺបងប្អូន ៧នាក់ គឺបានមកធ្វើការនៅរោងចក្រនេះ ៥ នាក់ហើយ ដោយសារតែនៅស្រុកមិនដឹងជាធ្វើអ្វី ទើបនាំគ្នាមកធ្វើការនៅរោងចក្រ នៅតាមផ្ទះតាមហាង ឲ្យតែរកបាន។

អ្នកនាងបានបន្តទៀតថា អ្នកនាងនិងបងប្អូន គឺសុទ្ធតែទទួលបានចំណែកដីកសិកម្មនៅខេត្ត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយដីចំណែកនោះវាតូចពេក ធ្វើអ្វីមិនកើត គឺម្នាក់ម៉ែចែកឲ្យត្រឹម ស្រែ ពីរស្រែបី ប៉ុន្តែដល់ពេលមានគ្រួសារ មានកូនរៀងៗខ្លួន បើនៅធ្វើស្រែបានអ្វីទទួលទានគ្រប់ ដូច្នេះ ខ្លះក៏លក់ ខ្លះក៏ទុកធ្វើផ្ទះ ហើយចេញមករកការងារធ្វើនៅទីក្រុងទាំងអស់គ្នាទៅ។

អ្នកនាង សេងទៀង បានបញ្ជាក់ថា "សព្វថ្ងៃនេះ បើមិនបានរោងចក្រធ្វើទេ មិនដឹងបានអ្វីស៊ីឲ្យគ្រប់ទេ"។

អ្នកនាង បានបន្តថា សព្វថ្ងៃនេះអ្នកនាងកំពុងតែរស់នៅបន្ទប់ជួលគេ ជាមួយនឹងប្តី ព្រមទាំងកូន ២នាក់ ហើយស្វាមីរបស់អ្នកនាង គឺជាអ្នករត់ម៉ូតូឌុប។

ជុំវិញបញ្ហាការងារធ្វើនេះ លោក គុប ច័ន្ទតឿ ជាកម្មករដើរតាមឡានដឹកទឹកកកមួយរូបបានឲ្យដឹងថា ម្នាក់ៗគ្មានអ្នកណាចង់នៅស្រុកទេ ដោយសារតែវាអត់អ្វីធ្វើ ជាពិសេសអ្នកដែលមានដីតិចតួចអត់មុខរបរ។ លោកបានរៀបរាប់ថា លោក គឺជាអ្នកស្រុកមកពីខេត្តកំពង់ធំ នៅម្តុំភ្នំសន្ទុក ដែលជារមណីដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រមួយ នៅតាមបណ្តោយផ្លូវជាតិលេខ៦ A។

លោកបានបញ្ជាក់ថា "អ្នកដែលគេមានរបរនេះរបរនោះនៅស្រុកបាន គេចេះតែនៅទៅ ប៉ុន្តែខ្ញុំបើនៅស្រុក ដាច់ពោះបាត់ហើយ"។

លោកបានបន្តថា មនុស្សវាកើន ការងារនៅស្រុកវាអត់ចឹងឲ្យតែពេញកម្លាំង ល្មមៗមិនបានរៀន បានសូត្រអីនឹងគេជ្រៅជ្រះទេ គឺចេញមករកការងារធ្វើចិញ្ចឹមជីវិតអស់ហើយ ។

លោកបានបន្តទៀតថា នៅឯស្រុកធ្វើអីរស់សម្រាប់គ្រួសារលោក ប៉ុន្តែអ្នកខ្លះគេអាចរស់នៅស្រុកបាន ដោយសារតែគេមានទុន គេធ្វើជំនួញនេះជំនួញនោះ ខ្លះទៅធ្វើតូបលក់អីវ៉ាន់ លក់អីនៅតាមរមណីដ្ឋាននោះ ហើយអ្នកខ្លះគេមានដីធ្លីច្រើន បានគេធ្វើស្រែ តែអ្នកដែលអត់អីដូចជារូបលោក និងគ្រួសារ គឺខ្លះទៅ ចេញមកធ្វើរោងចក្រកាត់ដេរនៅភ្នំពេញ ហើយខ្លះទៀតជាពិសេសក្មេងៗ គឺធ្វើការបម្រើគេនៅតាមផ្ទះ មើលក្មេង ខ្លះទៅចេញទៅរកការងារធ្វើនៅសៀមរាប ខ្លះក៏ទៅថៃក៏មានច្រើនដែរ ហើយចំណែករូបលោកនេះ គឺដើរបើកឡានដឹកទឹកកកឲ្យគេនៅភ្នំពេញចឹងទៅ។

លោកបានបន្តទៀតថា "យើងជាកូនអ្នកស្រែ អ្នកខ្សត់ រៀនមិនបានច្រើននឹងគេ រៀនចប់ត្រឹមថ្នាក់ទី៩អី បានការងារធ្វើប៉ុណ្ណឹងសមរម្យហើយ"។

លោក រឿន ចាន់ណា ដែលជាកម្មករសំណង់វ័យ ២៤ឆ្នាំ ដែលមានជំនាញខាងបូកស៊ីម៉ង់ក៏បានឲ្យដឹងដែរថា សម័យមុនអ្នកក្រ បានគេនៅស្រែ តែឥឡូវនេះ អ្នកនៅស្រែមិនមែនជាអ្នកក្រទេ។ លោកបានបន្តថា អ្នកនៅជនបទ មានមុខរបរនៅជនបទ មិនមែនអ្នកក្រទេ ពួកគេមានដី មានចំការ មានមុខរបរធំដុំ អ្នកដែលល្មមៗទេ ដែលនៅស្រែមិនកើត ពីព្រោះវាអត់អីរស់។ ស្រែក៏តិច មាត់ច្រើន ការងារមិនសូវសម្បូណ៌ ដូច្នេះហើយបានជាអ្នកនៅស្រែ ឲ្យតែពេញកម្លាំង គឺនាំគ្នាមករកការងារធ្វើនៅតាមទីក្រុង ទៅថៃអស់ហើយ។

ចាន់ណា បានអះអាងថា ផ្ទះខ្លួនដែលមានទីតាំងនៅស្រុកបាភ្នំ ខេត្តព្រៃវែង ចេញឡើងស្ងាត់ភូមិ អ្នកនៅភូមិ មានតែក្មេងតូចៗ ចាស់ៗ និងអ្នកដែលមានជីវភាពគ្រាន់តែប៉ុណ្ណោះ ដោយពួកគេចេញទៅរកការងារធ្វើ ហើយខ្លះទៀតទៅថៃ ទៅកូរ៉េ ទៅម៉ាឡេ...។

ទាំងនេះ គឺជាស្ថានភាពពិតរបស់បងប្អូនកម្មករ និងកម្មការិនីដែលកំពុងតែបម្រើការងារនៅរាជធានីភ្នំពេញ និងនៅតាមទីប្រជុំជន ដែលយើងបានទទួលព័ត៌មានតាមរយៈការប្រាស្រ័យទាក់ទង ជាមួយនឹងពួកគាត់ ប៉ុន្តែប្រសិនបើសួរគាត់អំពីអនាគត អំពីការវិវដ្តរបស់ស្រុកទេស គឺម្នាក់ៗគិតតែត្រឹមបច្ចុប្បន្នប៉ុណ្ណោះ។

ទាក់ទងនឹងសភាពការណ៍ស្រុកទេស គឺថា មានការដាក់សំពាធពីសំណាក់រដ្ឋាភិបាលនៅបស្ចិមប្រទេសមួយចំនួនទៅលើស្ថានភាពនៃការវិវដ្តនៃនយោបាយនៅកម្ពុជា ដែលកើតឡើងជាបន្តបន្ទាប់ក្រោយការរំលាយគណបក្សប្រឆាំង ដែលត្រូវបានអាជ្ញាធរអះអាងថា គណបក្សនេះខុសច្បាប់ ដោយគប់គិតជាប្រព័ន្ធជាមួយនឹងបរទេស ដើម្បីផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា។ រហូតដល់ករណីលើកឡើងអំពីលទ្ធភាពនៃការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការកាត់ជំនួយជាដើម ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយរឿងទាំងនេះអាចជារឿងឈឺក្បាលសម្រាប់តែបញ្ញាវន្ត និងអ្នកនយោបាយក៏ដូចជាមន្ត្រី ប៉ុន្តែសម្រាប់បងប្អូនកម្មករដូចជា មិនសូវជាចាប់អារម្មណ៍រឿងនេះទេ។

នៅពេលអ្នកនាំសារសួរអ្នកនាង សេងទៀង អំពីបញ្ហា និងការព្រួយបារម្ភអំពីរឿងទាំងនោះ អ្នកនាងបានត្រឹមតែញញឹមៗ និងនិយាយថាមិនដឹង។

អ្នកនាង បានបញ្ចេញសំឡេងថា "ខ្ញុំមិនដឹងនិយាយថា ម៉េចទេ ពីព្រោះមិនដឹង។ បើវាកើតរឿងអីទៅ តាមគេតាមឯងទៅ "។

លោក ច័ន្ទតឿ ក៏បានបញ្ចេញយោបល់ប្រហាក់ប្រហែលគ្នាថា "កាលណាកាលហ្នឹងទៅ គេម៉េច យើងម៉េច តាមតែគេតាមតែឯងទៅ។ មិនដឹងនិយាយថាម៉េចទេ.... វាមិនដឹង"។

ចាន់ណា ក៏ដូចគ្នា ដោយគ្រាន់តែអះអាងថា មិនដឹងធ្វើម៉េចទេ មិនដែលដឹងរឿងអីផង គ្រាន់តែថា បើអត់ការងារធ្វើមួយកន្លែងទៅរកមួយកន្លែងទៀតទៅ៕

*ដោយ អរិយបុត្រ*



*ថតដោយ: សហការី ស៊ីអេសស៊ី*

# ព្រឹទ្ធសមាជិកនីតិកាលទីបួន៤ត្រូវបានបោះឆ្នោតរួចរាល់



រូបភាពពីហ្វេសប៊ុក សម្តេច ហ៊ុន សែន

កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ អ្នកដែលមានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ចំនួន ១១.៦៧០នាក់ ឬ៩៩,៧៩% នៃអ្នកដែលមានសិទ្ធិបោះឆ្នោត សរុប ១១.៦៩៥រូប បានបោះឆ្នោតចប់ជាស្ថាពរ នៅការិយាល័យបោះឆ្នោតចំនួន៣៣កន្លែង។

ការបោះឆ្នោតនេះ មានការចូលរួមចំនួន ៤គណបក្ស គឺគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច គណបក្សយុវជនកម្ពុជា និងគណបក្សខ្មែររួបរួមជាតិ។

យោងទៅតាមរបាយការណ៍បឋមពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឲ្យដឹងថា គណបក្សប្រជាជនកម្ពុជា ទទួលបានការគាំទ្រចំនួន ១១.២០២ សំឡេង គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ២៧៦ សម្លេង គណបក្សខ្មែររួបរួមជាតិទទួលបាន ១៨២ សម្លេង និងគណបក្សយុវជនកម្ពុជាទទួលបាន ៣ សំឡេង។ ផ្អែកតាមលទ្ធផលនេះ គណបក្សប្រជាជនកម្ពុជា គឺទទួលបានអាសនៈ ទាំងអស់ចំនួន ៥៨ ។

បន្ទាប់ពីការបោះឆ្នោតនេះតទៅ ព្រះមហាក្សត្រ នឹងជ្រើសតាំងសមាជិកព្រឹទ្ធសមាជិក ២រូប ហើយរដ្ឋសភា ក៏នឹងជ្រើសតាំង ព្រឹទ្ធសមាជិក ២ រូបថែមទៀតផងដែរ ដូច្នេះសរុបទៅ កម្ពុជានឹងមានព្រឹទ្ធសមាជិក សរុបទាំងអស់ ៦២ រូប ពោលគឺច្រើនជាង នីតិកាលមុន មួយរូប ។

លោក ឌុច សុន សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងជាប្រធានដឹកនាំ អង្គប្រជុំ ស្តីអំពី ការសរុបព្រឹត្តិការណ៍ទូទៅនៅថ្ងៃបោះឆ្នោតនេះ បានថ្លែងថា ការបោះឆ្នោតនេះ បានប្រព្រឹត្តទៅដោយរលូន ក្នុងបរិយាកាសស្ងប់ស្ងាត់ គ្មានអំពើហិង្សា ដោយមានការការពារសន្តិសុខ សុវត្ថិភាពពីអាជ្ញាធរមានសមត្ថកិច្ច ។

គ.ជ.បបានប្រកាសថា ការបោះឆ្នោតនេះ គឺបានប្រព្រឹត្តទៅ ដោយមានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិប្រមាណជា ៣០០នាក់ ព្រមទាំងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិសរុបចំនួន ប្រមាណ ជាជាង ៣០០ នាក់ថែមទៀត ។

សមាជិកព្រឹទ្ធសភាឯទៀតត្រូវជ្រើសតាំង ដោយការបោះឆ្នោតអសកលមិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវបែងចែកជា ៨ ភូមិភាគ គឺ ភូមិភាគទី១ រាជធានីភ្នំពេញ មាន ៦ អាសនៈ ភូមិភាគទី២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន ៨អាសនៈ ភូមិភាគទី៣ ខេត្តកណ្តាល មាន ៥អាសនៈ ភូមិភាគទី៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន មាន ១០អាសនៈ ភូមិភាគទី៥ ខេត្តតាកែវ កំពត និងកែប មាន ៧អាសនៈ ភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ៧អាសនៈ ភូមិភាគទី៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ មាន ៩អាសនៈ និងភូមិភាគទី៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី មាន ៦ អាសនៈ។

គួររំលឹកថា ព្រឹទ្ធសភានៃកម្ពុជា ដែលជាអង្គនិតិប្បញ្ញាតិកំពូលមួយនៅកម្ពុជា ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ដែលមានអាណត្តិ ៥ឆ្នាំ ប៉ុន្តែត្រូវបានបន្តអាណត្តិរបស់ខ្លួន១ឆ្នាំទៀត គឺនៅឆ្នាំ២០០៥។ នៅសម័យកាលនោះ ព្រឹទ្ធសភានីតិកាលទី១ គ្មានការបោះឆ្នោតទេ គឺជាព្រឹទ្ធសភាចាត់តាំង ដោយមានសមាជិកចំនួន៦១ រូបកើតចេញពីការចាត់តាំង និងជ្រើសតាំងពីព្រះមហាក្សត្រ គណបក្សនយោបាយដែលមានអាសនៈនៅសភា។ ព្រឹទ្ធសភានីតិកាលទី១ នេះ គឺមាន២រូប តែងតាំងដោយព្រះមហាក្សត្រ។ គណបក្សប្រជាជនកម្ពុជាជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន ៣១រូប។ គណបក្សហ៊្វុនស៊ិនប៉ិច ជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន ២១រូប និងគណបក្សសម រង្ស៊ី ជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន ៧រូប។

ព្រឹទ្ធសភានីតិកាលទី២ និងនីតិកាលទី៣ សមាជិកកើត ឡើងតាមរយៈការបោះឆ្នោតអសកល និងមានអាណត្តិ ៦ឆ្នាំ។ សមាជិកព្រឹទ្ធសភា នីតិកាលទី២ និងនីតិកាលទី៣ មានសមាជិកចំនួន ៦១រូប ដូចគ្នាក្នុងនោះមានសមាជិកចំនួន ៥៧រូប ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល និងសមាជិក ៤រូបទៀតគឺ ២រូប ចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀត ជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើន ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី២ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ដោយគណបក្សប្រជាជនកម្ពុជា ទទួលបាន៤៥អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ១០អាសនៈ និងគណបក្សសម រង្ស៊ី ទទួលបាន២អាសនៈ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២។ សមាជិកដែលកើតចេញពីការបោះឆ្នោតអសកលនេះ រួមមាន គណបក្សប្រជាជនកម្ពុជា មានសមាជិក ៤៦រូប និង គណបក្ស សម រង្ស៊ី មានសមាជិក ១១រូប៕

*ដោយ អរិយបុត្រ*

# តើគំនិតផ្តួចផ្តើមដើម្បីសមាហរណកម្មអាស៊ាន ( IAI ) ជាអ្វី ?

គំនិតផ្តួចផ្តើមដើម្បីសមាហរណកម្មអាស៊ាន ដែលមានអក្សរកាត់ជាភាសាអង់គ្លេសថា IAI នេះ គឺជាគំនិតផ្តួចផ្តើមមួយរបស់បណ្តាមេដឹកនាំអាស៊ាន ដែលបានដាក់ចេញ កាលពីកិច្ចប្រជុំកំពូលឆ្នាំ២000 ដើម្បីកាត់បន្ថយគន្លាតនៃការអភិវឌ្ឍន៍និងពង្រឹងការប្រកួតប្រជែងរបស់អាស៊ាន ។

នេះអាចជាក្របខណ្ឌថ្នាក់តំបន់មួយដើម្បីជំរុញកិច្ចសហប្រតិបត្តិការណ៍ដើម្បីជួយបណ្តាប្រទេស សមាជិកអាស៊ានថ្មី ដែលមានដូចជា កម្ពុជា ឡាវ ភូមា និង វៀតណាម ។

យោង ទៅតាមឯកសារបណ្តាប្រទេសអាស៊ាន ចាស់ គឺប្រទេសសិង្ហបុរី បានដើរតួនាទីសំខាន់បំផុត នៅក្នុងយន្តការ ជួយគាំទ្រនូវគំនិតផ្តួចផ្តើមដើម្បីសមាហរណ-កម្មអាស៊ាននេះ ។

ជាការពិតប្រសិនបើយើងប្រៀបធៀបអំពីសក្តានុពលសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាង អាស៊ាន ចាស់ ដែលមានសិង្ហបុរី ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន និង ប្រ៊ុយណេ ប្រទេសទាំងនេះ មានសក្តានុពលលើសប្រទេសអាស៊ានថ្មី ដូចជា កម្ពុជា ឡាវ ភូមា និងវៀតណាម ឆ្ងាយ នៅលើផ្នែក ធនធានមនុស្ស និងធនធានសេដ្ឋកិច្ច ព្រមទាំងហេដ្ឋារចនាសម្ពន្ធរូបវ័ន្តផ្សេងៗទៀត ដូច្នេះហើយបានជា គំនិតផ្តួចផ្តើមនេះ ត្រូវបានកកើតឡើង ដើម្បីជួយដល់ប្រទេសកម្ពុជា និងបីផ្សេងទៀត ឲ្យមានភាពស្មើមុខ ស្មើមាត់នឹងបណ្តាប្រទេសនៅក្នុងតំបន់តាមរយៈផែនទីវិថីមួយ ដើម្បីឈានទៅទទួលបានផលប្រយោជន៍ និងឧត្តមភាពអាស៊ានមួយទាំងអស់គ្នា។

ឆ្លងតាមគំនិតផ្តួចផ្តើមនេះ បណ្តាប្រទេសអាស៊ានក៏បានឈានទៅអនុម័តប្រកាសអាស៊ាន ដែលពីមុន គឺជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនោះ ឲ្យទៅជាសហគមន៍អាស៊ាន កាលពីឆ្នាំ២០១៥ កន្លងទៅ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែលក្ខខណ្ឌនយោបាយ សេដ្ឋ-កិច្ច ធនធានមនុស្ស វប្បធម៌ ទីផ្សារ វាខុសគ្នា ផែនការនេះនៅមិនទាន់បានសម្រេចទាំងស្រុងនៅឡើយទេដូច្នេះ ហើយបានជាមេដឹកនាំអាស៊ាននៅតែបន្តយកចិត្តទុកដាក់ចំណុចនេះបន្ថែមទៀត ហើយក៏មានផែនការ ការងារ ជាច្រើនត្រូវបានអនុម័តដោយមេដឹកនាំអាស៊ានទាំង ១០ ដោយនៅក្នុងនោះ កាលពីឆ្នាំ២០១៦ បណ្តាមេដឹកនាំអាសាន ក៏បានអនុម័តនូវផែនការការងារដំណាក់កាលទីបី នៃគំនិតផ្តួចផ្តើមដើម្បី សមាហរណកម្មអាស៊ាន ( IAI Work Plan III ) ។

ផែនការការងារនេះ គឺមានរយៈពេលពីឆ្នាំ២០១៦-២០២០ ដោយផ្តោតសំខាន់នៅលើយុទ្ធសាស្ត្រ ៥ ដែលរួមមាន ស្បៀងនិងកសិកម្ម ការសម្របសម្រួលពាណិជ្ជកម្ម ការលើកកម្ពស់និងការពង្រឹងសហគ្រាសធុនតូចនិងមធ្យម អប់រំនិងសុខភាព និងសុខមាលភាព។

អនុវត្តតាមគំនិតផ្តួចផ្តើមនេះ មានគម្រោងជាច្រើន ត្រូវបានដាក់ចេញ ដើម្បីជួយដល់ ប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម ដើម្បីពង្រឹងចំណេះដឹង និងការយល់អំពីវិស័យការងារសំខាន់ៗនាអាស៊ាន សម្រាប់មន្ត្រី ឬអ្នកសេវាកម្មគន្លឹះចម្បងៗ។ ក្រៅពីនោះ គម្រោងការងារនេះក៏បានជួយតម្រង់គោលដៅអភិវឌ្ឍន៍ និងការធ្វើបច្ចុប្បន្នភាពនៃច្បាប់ ក៏ដូចជាលិខិតបទដ្ឋាននានា ដើម្បីឲ្យវាស៊ីគ្នាទៅនឹងការប្តេជ្ញាចិត្តនៅក្នុងតំបន់។

គំនិតផ្តួចផ្តើមនេះ ក៏រួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលជំនាញ និងកម្រិតក្រោយឧត្តមនៅក្នុងប្រទេសទាំងបួន ការពង្រឹងវិស័យធុរកិច្ច សេវាកម្ម ការកសាងបណ្តាញ សម្រាប់តំបន់រវាង ប្រទេសទាំងបួន និងបណ្តាប្រទេសអាស៊ានចាស់ទាំង៦ ។

អាស៊ាន ត្រូវបានគេដឹងថា បានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧នៅទីក្រុងបាងកក ប្រទេសថៃ ។ ប្រទេសដែលជាស្ថាបនិកអង្គការតំបន់នេះគឺមាន ថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី។ ក្រោយមកប្រទេសប្រ៊ុយណេបានចូលរួមអង្គការតំបន់មួយនេះ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៨៤។ ក្រោយមក នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥ វៀតណាម បានចូលរួម ហើយ ប្រទេស ឡាវ និងភូមា បានចូលរួមបន្តទៀតនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧ ខណៈកម្ពុជា បានចូលរួមនៅអាស៊ាន កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ បច្ចុប្បន្ននេះកម្ពុជា គឺកំពុងតែជាកូនពៅរបស់អាស៊ាន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រទេសមួយចំនួន ក៏កំពុងតែដុតដៃដុតជើងចង់ក្លាយជាសមាជិកអាស៊ានដែរគឺ ប្រទេសទីម័រខាងកើត និង ប្រទេសប៉ាពួរញូវហ្គេណេ៕

*ដោយ អរិយបុត្រ*



# កូរ៉េនឹងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គនៅកម្ពុជា

ក្រសួងការបរទេសកាលពីថ្ងៃទី១២ មីនា ២០១៨ បានប្រកាសថា រដ្ឋាភិបាលនៃប្រទេសកូរ៉េខាងត្បូងបាន ឆ្លើយតបហើយនឹងសំណើរសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការ កសាងស្ពានឆ្លងកាត់ទន្លេមេគង្គ ។

គម្រោងនេះត្រូវបានបង្កើក នៅក្នុងពេលដែល លោក ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការ បរទេសបានទទួលជួបលោក អូ ណាក យ៉ាន ឯកអគ្គ-រដ្ឋទូតកូរ៉េខាងត្បូងប្រចាំនៅកម្ពុជា កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ។

ប្រភពដដែលបានបន្តថា "ក្នុងការពិភាក្សាអំពីទំនាក់-ទំនងទ្វេភាគី លោក ទេសរដ្ឋមន្ត្រី បានសម្តែងកតញ្ញូតា ចំពោះជំនួយឧបត្ថម្ភលើគ្រប់វិស័យ ដែលរដ្ឋាភិបាលកូរ៉េ បានផ្តល់ជូនកម្ពុជា និងបានវាយតំលៃខ្ពស់ចំពោះការ ឆ្លើយតបរបស់រដ្ឋាភិបាលកូរ៉េទទួលយកសំណើសម្តេច តេជោនាយករដ្ឋមន្ត្រី ជួយសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េ ឆ្លងកាត់ទន្លេមេគង្គ"។

មិនមានព័ត៌មានលំអិតថា ស្ពានថ្មីនោះ នឹងសាងសង់ នៅទីណា នៅកន្លែងណា ហើយគម្រោងនោះ មានទឹក ប្រាក់ ប៉ុន្មានឡើយ ។

រហូតដល់ពេលនេះគេដឹងថាស្ពានឆ្លងកាត់ទន្លេធំៗ ភាគច្រើននៅកម្ពុជា ត្រូវបានកសាងឡើងដោយ ជប៉ុន និង ប្រទេសចិន៕

# សាស្ត្រាចារ្យមួយរូបរងរបួសជាដំណំដោយសារតែអំពើហិង្សាក្នុងករណីគ្រោះថ្នាក់ចរាចរណ៍

សាស្ត្រាចារ្យនៅសាកលវិទ្យាល័យកម្ពុជាមួយរូបបាន រងរបួសយ៉ាងដំណំ ដោយសារតែអំពើហិង្សា ដែលបង្ក ឡើងដោយមហាជន ក្រោយពេលកើតហេតុគ្រោះថ្នាក់ ចរាចរណ៍។

សាស្ត្រាចារ្យរូបនោះ ត្រូវបានគេដឹងថា ឈ្មោះ លោក បណ្ឌិត ស៊ុយ សារ៉េត បានរងរបួសដោយមានឈាម ដោតខ្លួន ក្រោយពេលដែលរូបលោក ត្រូវបានគេដឹងថា បានបើករថយន្ត កើតមានករណីគ្រោះថ្នាក់ ចរាចរណ៍ មួយករណី ប៉ុន្តែមិនឈប់ ក៏បន្តដំណើរ ហើយក៏ត្រូវ បានប្រជាពលរដ្ឋដេញតាម ហើយ ក៏ប៉ះ ប្រជាពលរដ្ឋ តាមផ្លូវ បន្ថែមទៀត រហូតដល់ពេលដែលលោក ត្រូវបាន គេវាយយ៉ាងដំណំ នៅម្តុំក្រោយមន្ទីរពេទ្យព្រះសង្ឃ។

រថយន្តរបស់លោក ត្រូវប្រជាពលរដ្ឋ និងជនឱកាស និយមឆ្លៀតវាយកម្ទេច ហើយរូបលោកត្រូវបានក្រុម គ្រួសារ បញ្ជូនទៅសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យប្រទេស វៀតណាម តែពេលនេះពេទ្យបញ្ជាក់ថា មិនប៉ះពាល់ ក្បាលខ្លាំងនោះឡើយ។

តាមរបាយការណ៍នៃការខូចខាត គឺមិនមានព័ត៌មាន លំអិតអំពីជនរងគ្រោះដែលលោក បណ្ឌិតបាន ប៉ះនោះ ទេ ប៉ុន្តែសម្រាប់ខាង លោកបណ្ឌិត គឺមានរបាយការណ៍ ថា លោកបានបាត់បង់ថវិការជិត ៣០០០ ដុល្លារ ទូរស័ព្ទ ២ គ្រឿង។

បន្ទាប់ពីកើតហេតុហិង្សានេះ លោក ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាល រាជធានីភ្នំពេញ ក៏បានប្រកាសថា សមត្ថកិច្ចនឹងស្រាវ ជ្រាវរកអ្នកពាក់ព័ន្ធទាំងអស់ ដែលបានវាយប៉ងសម្លាប់ និងកម្ទេចរថយន្តជនរងគ្រោះ មកដាក់ទោសតាមច្បាប់។ ករណីគ្រោះថ្នាក់នេះ អ្នកបើកបរបង្កគ្រោះថ្នាក់ចរាចរណ៍ ដែលរត់គេចពីកន្លែងកើតហេតុ គឺច្បាប់ជាអ្នកអនុវត្ត ប៉ុន្តែចំពោះអ្នកដែលវាយអ្នកបើកបរ ក៏ត្រូវតែទទួល ទោសផងដែរ ព្រោះវាជាអំពើអសីលធម៌ក្នុងសង្គម និង មិនគួរឲ្យមានកើតឡើងក្នុងរូបភាពបែបនេះទៀត៕

# កម្ពុជានឹងធ្វើអាជីវកម្មរ៉ែនៅពេលឆាប់ៗនេះ

ប្រទេសកម្ពុជានឹងអាចធ្វើអាជីវកម្មលើរ៉ែមាសនៅក្នុង ខេត្តរតនគីរីនិងមណ្ឌលគីរី នៅពេលឆាប់ៗខាងមុខនេះបើ តាមលោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ថ្លែងនៅក្នុងសន្និបាតរយៈពេល២ ថ្ងៃដែលបាន ប្រព្រឹត្តកាលពីដើមខែ មីនា លោក ស៊ុយ សែម បាន មានប្រសាសន៍ថា ដំណើរការធ្វើអាជីវកម្មរ៉ែមាសនឹង ត្រូវអនុវត្តនាពេលឆាប់ៗនេះ។

លោកបានគូសបញ្ជាក់ថា "ការចាប់ផ្តើមនៃការធ្វើ អាជីវកម្មរ៉ែមាសនៅក្នុងខេត្តរតនគិរីនិងរបាយការណ៍ នៃការរុករករ៉ែមាសនៅអូរក្រាវ ខេត្តមណ្ឌលគីរីនាពេល ថ្មីៗនេះនឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាចាប់ផ្តើមផលិត កម្មមាសក្នុងពេលឆាប់ៗ" ។

ជុំវិញបញ្ហានេះ លោក យស់ មុន្នីរ៉ាត់ អគ្គនាយកនៃ អគ្គនាយកដ្ឋានរ៉ែ ក្រសួងរ៉ែ និងថាមពលបានឲ្យដឹងថា កម្ពុជាតាមគម្រោងការ គឺអាចផលិតមាសនៅឆ្នាំ២០១៩ ។

លោកបានឱ្យដឹងថាកម្ពុជាមានក្រុមហ៊ុនសរុបប្រមាណ ១០០ ក្រុមហ៊ុនកំពុងប្រតិបត្តិការរុករករ៉ែនៅតាមគោល-ដៅផ្សេងៗគ្នាក្រោមអាជ្ញាប័ណ្ណរុករករ៉ែ ប៉ុន្តែគ្មានក្រុមហ៊ុន ណាមួយអាចទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មបាន នៅឡើយ។

ក្រៅពីមាសកម្ពុជាក៏ជាប្រទេសសំបូរធនធានរ៉ែដទៃ ទៀតដែលរួមមានស្ពាន់ ដែក ស័ង្កសី បុកស៊ីត ជាដើម៕

# ជំងឺផ្តាសាយថ្មី អាចសម្លាប់មនុស្ស ៣៣ លាននាក់ក្នុងរយៈពេលតែ២០០ថ្ងៃ

អ្នកជំនាញខាងសុខាភិបាលម្នាក់បានអះអាងថា មនុស្ស ជាតិនឹងមិនអាចបញ្ឈប់ជំងឺផ្តាសាយមួយប្រភេទ ដែល អាចសម្លាប់មនុស្សដល់ទៅ ៣៣លាននាក់ ក្នុងរយៈ ពេលត្រឹមតែ ២០០ ថ្ងៃប៉ុណ្ណោះ។

លោក សាស្ត្រាចារ្យ រ៉ូប៊ីត ឌឹងវ៉ល ដែលជាអ្នកជំនាញ ការខាងសុខភាពមួយរូប បានប្រាប់កាសែត ឌឹសាន់ ថា វាលំបាកខ្លាំងណាស់ក្នុងការបញ្ឈប់ការរីករាលដាលនៃ ជំងឺគ្រុនផ្តាសាយនេះនៅពេលណាដែលវាចាប់ផ្តើមផ្ទុះ ឡើង ពីព្រោះមនុស្សអាចឆ្លងជំងឺនេះ ៤ថ្ងៃ មុនពេលវា បង្ហាញរោគសញ្ញា។

ការទស្សន៍ទាយដ៏ក្រៀមក្រំនេះគឺកើតឡើងតែ២ថ្ងៃ ប៉ុណ្ណោះ បន្ទាប់ពីវេជ្ជបណ្ឌិត ចូណាថាន គ្វីក អ្នកជំនាញ ផ្នែកវេជ្ជសាស្ត្រកំពូលម្នាក់របស់ពិភពលោក បានព្រមាន ថា ស្ថានភាពបច្ចុប្បន្នកំពុងអំណោយផលសម្រាប់ឱ្យ ជំងឺផ្តាសាយ ដែលអាចសម្លាប់មនុស្សរាប់លាននាក់ ចាប់ផ្តើមរីករាលដាលភ្លាមៗ។

លោកបានសរសេរកាលពីថ្ងៃអង្គារ ទី៦ ខែមីនាថា "ការឆ្លងរាតត្បាតដ៏ធំកំពុងជិតមកដល់ហើយ នោះគឺជា ការឆ្លងរាលដាលនៃវីរុសជាសកល ដែលអាចសម្លាប់ ជនរងគ្រោះ ៣៣លាននាក់ ក្នុងរយៈពេល ២០០ ថ្ងៃ ដំបូងរបស់វា"។

លោកសាស្ត្រាចារ្យឌឹងវ៉លបាននិយាយ ថា "ជំងឺផ្តា-សាយនេះពិតជាឆ្លងរាលដាលខ្លាំងសម្បើមណាស់ ហើយ គ្មានអ្វីច្រើននោះទេដែលអ្នកអាចធ្វើបាន ដើម្បីបញ្ឈប់វា កុំឱ្យគ្រាច់ចរជុំវិញផែនដីនេះ"។

ដោយសារតែបម្រែបម្រួលអាកាសធាតុ អ្នកវិទ្យា-សាស្ត្របានព្រមានថា ពិភពលោក កំពុងតែប្រឈមនឹង ការកើនឡើងនូវមេរោគនិង ជំងឺប្លែកៗ ហើយកាន់តែ សាហាវ៕

# ប្រជាពលរដ្ឋសូមប្រយ័ត្នណា ! រូបភាពបោកប្រាស់



រូបភាពឬទម្រង់នៃការបោកប្រាស់ គឺមានច្រើនរូបភាព និងច្រើនសណ្ឋាន ហើយមានទាំងខ្មែរ និងបរទេស រីឯរបៀប និងវិធីសាស្ត្រនៃការបោកប្រាស់នោះទៀត សោតក៏កាន់តែគួរឲ្យជឿ ជាក់ មែនទែន ដូច្នេះសូមបងប្អូនទាំងអស់មានការប្រុងប្រយ័ត្ន។ នេះ គឺជាសំដីរបស់បងប្រុសមួយរូប ដែលបានចែក រំលែកពីបទពិសោធន៍របស់គាត់។

លោក លាង ហេង ជាប្រជាពលរដ្ឋ អាយុ ៤០ឆ្នាំមួយរូប ដែលបានចែករំលែកបទពិសោធន៍ ដែលលោកផ្ទាល់ និងមិត្តភក្តិរបស់លោកបានជួបកន្លងមកថា សម័យមុន រូបភាពនៃការបោកប្រាស់របស់ជនបរទេសដែលគេបានដឹង គឺមានត្រឹមតែរបៀបនៃការផ្ញើសារអេឡិចត្រូនិចតាមរយៈអ៊ីម៉ែល មកចូលអ៊ីម៉ែលរបស់យើង ដោយរៀបរាប់រូបភាព ថាគេមានប្រាក់ចំនួនប៉ុណ្ណេះ ឬប៉ុណ្ណោះ ហើយគេចង់ធ្វើ និងសហការរកស៊ី នៅកម្ពុជា ឬចង់ចាប់ដៃគូជាមួយយើងដើម្បីបើកអាជីវកម្មណាមួយ។ ពេលឃើញសារបែបនេះ ប្រសិនបើយើងចាប់អារម្មណ៍ ហើយលុះទៅក្នុងសេចក្តីលោភលន់ ហើយទំនាក់ទំនងឆ្លើយ ឆ្លងជាមួយគេនោះ ពួកអ្នកបោកប្រាស់ទាំងនោះ ក៏ចាប់ផ្តើមទំនាក់ទំនងមកយើងគួរឲ្យជឿ ជាក់ រួចចុងក្រោយគឺគេតម្រូវឲ្យយើងវេលុយ ឲ្យគេប៉ុណ្ណេះ ឬប៉ុណ្ណោះ ដើម្បីរត់ការឯកសារ។

លោកបានបន្តថា មធ្យោបាយបែបនោះ ក៏មានពលរដ្ឋកម្ពុជាមួយចំនួនចាញ់កលឧបាយរបស់គេមិនតិចនោះទេ។ ក្រោយមកទៀត គេបានប្តូរបន្តិច ដោយគេអភិវឌ្ឍន៍មកជារូបភាពទំនាក់ទំនង ស្រដៀងគ្នានេះដែរ ប៉ុន្តែគេមិនស្នើសុំ ឲ្យយើងវេលុយឲ្យគេត្រង់ៗនោះទេ គឺប្រើរូបភាពជាការស្នើសុំលេខគណនី ហើយបន្ទាប់មក ក៏លេខវីសាខាតហើយ ក៏លេខកូដសម្ងាត់។

លោកបានបន្តទៀតថា ក្រោយមកទៀត រូបភាពនេះ បានកាន់តែទំនើប ដោយពួកជនខិលខូចចាប់ផ្តើមព្យាយាម ស្វែងយល់ពីយើងម្នាក់ៗ យ៉ាងច្បាស់ ដោយ គេដឹងគោលដៅបោកប្រាក់នោះច្បាស់ពោល គឺដឹងតាំងពីមុខរបរ កន្លែងធ្វើការ លេខទូរស័ព្ទ ធ្វើបីដូចជាគេស្គាល់យើងច្បាស់ ហើយក៏បានទំនាក់ទំនងមកយើង តាមការសរសេរសំបុត្រ ផ្ញើតាមក្រុមហ៊ុនប្រៃសណីយ៍ មកយើងដោយរៀបរាប់ពីការងាររបស់គេ ហើយគេចាប់អារម្មណ៍ និងការងាររបស់យើង ហើយចង់សហការ ដោយតម្រូវឲ្យយើង សរសេរគម្រោងការងារអាជីវកម្ម ឬបេសកម្មមនុស្សធម៌ ដូចជារបៀបម្ចាស់ជំនួយដែលមានលុយ រាប់លានដុល្លារមកយើង ហើយឲ្យយើងផ្ញើជូនគេ។ បន្ទាប់ពីយើងផ្ញើឲ្យគេតាមអាស័យដ្ឋានទំនាក់ទំនងត្រឹមត្រូវ មានអ៊ីម៉ែលមានអស័យដ្ឋាន ច្បាស់លាស់ មានលេខទូរស័ព្ទ ឲ្យពួកគេ ពួកគេក៏បានឆ្លើយតបមកជាបន្តបន្ទាប់តាម ជំហានការងារជំនាញ ប៉ុន្តែចុងក្រោយ គឺជាច់ខាតដើម្បីទទួលបានទឹកប្រាក់ជំនួយ ឬការរួមហ៊ុនអាជីវកម្ម គឺពួកគេតម្រូវឲ្យយើងត្រូវផ្ញើលុយ ឬវេលុយឲ្យគេរត់កាត់ ឬលេខគណនី និងឯកសារ ដែលល្មមគ្រប់គ្រាន់នឹងពួកគេអាចយកលុយពីយើងបាន។

លោកក៏បានចែករំលែកបន្តទៀតថា ទាំងនេះ គឺជាល្បិច និងវិធីសាស្ត្រនៃការបោកប្រាស់ដែលធ្លាប់មានពលរដ្ឋមួយចំនួនបានជួបប្រទះ ដោយខ្លះបានបាត់បង់ប្រាក់កាស់ និងធ្លាប់ខាតពេលវេលាជា

## វិធានការណ៍ការពារល្បិចបោកប្រាស់

យោងតាមបណ្តាញសង្គមអ្នកសរសេរប្លកមួយដែលមានអស័យដ្ឋាន ថា sopheaksrey.wordpress.com បានចែករំលែកថា អ្នកដែលព្យាយាមបោកយើង គឺគេគ្មានទទួលព័ត៌មានពីណា ក្រៅពី អ្វីដែលយើង លេង អ៊ីនធើណែត លេងបណ្តាញសង្គមនោះទេដូច្នេះសូមប្រយ័ត្ន ។

ប្រភពនោះ បានចែករំលែកថា យើងម្នាក់ៗអាចភ្លេចពួកអ្នកចាំបោកនោះ តែពួកគេមិនដែលភ្លេចយើងទេ ហើយពិតណាស់ "វាមិនសំខាន់ថា វិធីចាស់គំរិលឡើយឱ្យតែមានប្រសិទ្ធិភាព គឺជាវិធីដ៏ល្អហើយ"។ ពួកគេរង់ចាំឱកាស ដើម្បីបោកប្រាស់យើងដូច្នេះយើងត្រូវប្រាកដចិត្តថា"យើងមិនមែនជាមនុស្សលោភលន់"ទើបអាចគេចផុតពីអន្ទាក់របស់ពួកគេ។ហើយសូមប្រយ័ត្នរាល់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដែលត្រូវបាន បង្ហោះផ្សាយជាសាធារណៈ។

ប្រភពដដែលបានបន្តថា អ៊ីនធើណែត ពិតណាស់ អាចងាយស្រួលស្រាវជ្រាវ និងទំនាក់ទំនងគ្នា តែពេលខ្លះក៏គ្រោះថ្នាក់ដែរ។ រាល់ព័ត៌មាន និងទំនាក់ទំនង នៅលើបណ្តាញឥតខ្សែមួយនេះ មិនធានាបាននូវសុវត្ថិភាពពេញលេញឡើយ។ អ្នកអាជីព ខាងបោកលើ បណ្តាញអ៊ីនធើណែត បានប្រើប្រាស់វិធីដដែលៗ ដូចជា ច្រោះចូលអ៊ីម៉ែលរបស់យើងហើយផ្ញើសារដើម្បីសុំ ជំនួយពីមិត្តអ្នកនៅក្នុង បញ្ជីទំនាក់ទំនង ផ្ទាល់ខ្លួន ដែលមានស្រាប់។ អ៊ីម៉ែល ឬផ្ញើសារ អបអរសាទរថា យើងឈ្នះរង្វាន់ រាប់ពាន់ រាប់សែន រហូតដល់រាប់លានដុល្លារ ហើយស្នើឱ្យអ្នកបំពេញឈ្មោះ និងលេខទូរស័ព្ទទំនាក់ទំនង។ បើយើងហ៊ានតែឱ្យលេខទំនាក់ទំនងទៅពួកគេធានា ថាទូរស័ព្ទមកអ្នកភ្លាមហើយអត់មានលោះពេលទេសុទ្ធតែ ០០១(មកពីបរទេស ឬតាមអ៊ីនធើណែត)។ ចុងក្រោយ ពួកគេ តម្រូវឱ្យ អ្នកបង់ប្រាក់ ថ្លៃបំពេញ ពាក្យ ឬធានា ការផ្ទេរប្រាក់ ជាដើម។ មានតែអ្នកមិនចេះ អង់គ្លេស ទេ ទើបអាចរួចខ្លួនព្រោះមិនដឹង ពួកគេនិយាយស្អី។

# ប់ឥឡូវកាន់តែគួរឲ្យជឿជាក់



ច្រើនជាមួយនឹងពួកគេ ប៉ុន្តែរូបភាពថ្មីៗមួយទៀត នោះគឺកាន់តែជឿទុកចិត្តទៅទៀត ដែលយើងខ្ញុំគិតថា វារិតតែគ្រោះថ្នាក់សម្រាប់សង្គមកម្ពុជាយើង ។

លោក លាង ហេង សង្កត់ធ្ងន់នឹងករណីថ្មីនោះថា "សូមប្រយ័ត្ន ! រូបភាពថ្មីនោះគឺពួកគេ (ពួកអ្នកបោកប្រាស់) មានរហូតដល់ជាស្គាល់លេខទូរស័ព្ទមកយើង ហើយលេខទូរស័ព្ទ នោះគឺមានទំនាក់ទំនងមកពីប្រទេសជាច្រើន តាមច្រក០០១ ក៏មាន ០០៧ ឬច្រកផ្សេងៗក៏មាន ហើយបើយើង អាចឆែកមើលទៅលេខទូរស័ព្ទនោះ គឺពិតជាទំនាក់ទំនងមកពីអាមេរិកពីប្រទេសណាមួយពិតប្រាកដ ដែល ពួកអ្នកបោកប្រាស់អាជីពទាំងនោះ ទំនាក់ទំនងមកយើងតាមរបៀប ដូចជា ប្រទ្បំ លេខ ហើយក៏គេចង់ទំនាក់ទំនងរាប់អាន។ បន្ទាប់មកពួកគេព្យាយាមទំនាក់ ទំនងមកយើង ជាច្រើនលើកច្រើនសារ តាមរូបភាពដូចជាចង់កសាងមិត្តភាពជាមួយនឹង យើងចង់រាប់អានយើងពិតប្រាកដ ហើយ ពួកគេព្យាយាមអូសក្រទ្បាយើង រហូតដល់ អាចបាក់ជាមួយនឹងពួកគេ ក៏តាំងពួក គេអះអាងថា ពួកគេនឹង មកខ្មែរយើង ដោយណាត់ជួប យើងនៅកន្លែងនេះ កន្លែងនោះតាមការណាត់ជួប។ ហើយបើយើងទៅតាមការណាត់ជួបនោះគឺថា ពួកគេពិតជាមកជួបយើងមែន ប៉ុន្តែនោះអាចជាបណ្តាញរបស់ពួកគេ ដែលមាន ស្រាប់ហើយអ្នកដែលមកជួបយើងនោះ ភាគច្រើនជាជនជាតិបរទេសស្បែកខ្មៅ ដែលអាចថា ពួកគេនៅកម្ពុជាយើងស្រាប់។ ការជួបនេះ គឺអាចអូសបន្លាយពេលវេលា និងណាត់ជួបគ្នា ច្រើនលើកដែរ ហើយពួកគេក៏តាំងសួរយើងថាចង់បានអ្វីរួចពួកគេហ៊ានចំណាយ ឲ្យយើងទាំងអស់ ដោយរួមទាំងវត្ថុមានតម្លៃ ជាខ្សែករ ជាវត្ថុមែនទែនសុទ្ធៗមិនមែនកាឡៃនោះទេ។ ហើយក៏នៅរក្សាទំនាក់ទំនងមកយើងជាធម្មតា ជាបន្តបន្ទាប់ ប៉ុន្តែចុងក្រោយនៅតែ លានកន្ទុយមក ប្រសិនបើយើងគិតពិចារណាឲ្យបានហ្មត់ចត់គឺគ្មានអ្វី ក្រៅពីពួកគេមកលេងស្រុកយើង គេបាត់កាបូប បាត់អត្តសញ្ញាណ-ប័ណ្ណបាត់ អ្វីៗអស់ ហើយសូមឲ្យយើងជួយគេប៉ុណ្ណេះ ប៉ុណ្ណោះ ឬមួយក៏ពួកគេ ឲ្យយើងវេលុយ តាមរូបភាពមុនៗដដែល"។

លោកបានបញ្ជាក់ថា "ទាក់ទងអ្វី គឺទាក់ទងទៅ តែបើឈានដល់សុំឲ្យវេលុយ សុំលេខគណនី លេខសម្ងាត់ធនាគារ លេខវីសាកាតអី សូមប្រយ័ត្ន"។ លោកបានបញ្ជាក់ទៀតថា "អ្វីក៏ដោយ ឲ្យតែនិយាយរឿងលុយ គឺសូមប្រយ័ត្ន ហើយបើគេបបួលទៅនេះទៅនោះ ក៏សូមប្រយ័ត្នដែរ ពីព្រោះគេអាច បោកប្រាស់យើងឲ្យដួញដូរគ្រឿងញៀន ឬរបស់ខុសច្បាប់"។

លោក សួន ប្រជា ជាប្រជាពលរដ្ឋវ័យ ៥៥ឆ្នាំមួយរូបទៀត បានចូលរួមចែករំលែកខ្លីថា លោកធ្លាប់ទទួល អ៊ីម៉ែលច្រើន រឿងនេះ តែលោកមិនដែលរវល់ទេ ដោយគិតថា គ្មានអ្នកណាគេយកលុយ រាប់ម៉ឺន មកដើរសួររកឲ្យគេដូច្នេះទេ។

លោក ណែត សុផាត ជាមន្ត្រីរាជការមួយរូប បានបន្តទៀតថា លោកក៏ធ្លាប់ជួបរឿងទាំងនេះដែរ ហើយមានគេហៅទូរស័ព្ទពីបរទេសទៀតផង គេសុំឲ្យជួយ រឿងនេះ ប៉ុន្តែលោកបានអះអាងថា ប្រទ្បំលេខ ។

លោក សុផាត បានបញ្ជាក់ថា អារឿងចាញ់បោកគេនេះ គឺវាលុះតាមសេចក្តីលោភរបស់យើង ប៉ុន្តែរឿងមួយដែលត្រូវចាំ គឺថាវាមិនដែលនៅសុខៗ គេវេចលុយដើរមករកឲ្យគេស្រួលៗបែបនេះទេ។ ឃើញអត់ម៉ាខែៗ ធ្វើការអង្គុយឡើង ក្រិនគូទបានប្រាក់ខែខ្លះខ្វះរយ ហើយច្រើនបំផុតខ្ទង់ពាន់"។

មន្ត្រីនាយប៉ូលីសនៅបុស្តិ៍ មួយនៅខណ្ឌដូនពេញ ដែលសុំមិនបញ្ចេញឈ្មោះ បានឲ្យដឹងថា លោកធ្លាប់តែឮទេ ប៉ុន្តែមិនទាន់មាន ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់លោកណាម្នាក់ ប្តឹងករណីនេះនៅឡើយទេ ប៉ុន្តែក៏មានបទបញ្ជាពីថ្នាក់លើ ឲ្យយកចិត្តទុកដាក់រឿងនេះដែរ។

លោកបានបន្តថា "ខាងលើគេប្រាប់ឲ្យតាមមើល ដោយខាង អាំងទែប៉ូល (ប៉ូលីសអន្តរជាតិ) គេរាយការណ៍ ប៉ុន្តែមិនសង្កត់ធ្ងន់រឿងបោកប្រាស់ទេ គឺសង្កត់ធ្ងន់រឿងគ្រឿងញៀន និងភេរវកម្ម"។

លោកបានបន្តថា រឿងនេះវាអាចមានតែជារឿងកិត្តិយស ហើយមិនសូវក្តុងក្តាំងដូចប្លន់ ដូចលួច បានជាចេះតែស្ងាត់ៗក៏ថាបាន ៕

*ដោយ អរិយបុត្រ*

## ស្ថាប័នធនាគារក៏ធ្លាប់ព្រមានដែររឿងបោកប្រាស់នេះ

បើទោះបីជាមិនចំបញ្ហានៃករណីបោកប្រាស់នីមួយៗប្រាកដមែន ប៉ុន្តែធនាគារមួយចំនួនក៏បានចេញប្រកាសព័ត៌មានរំលឹកនិងដាស់តឿន អតិថិជន ក៏ដូចជាសាធារណជនអំពីល្បិចកល់នៃការបោកបាស្រ់នេះមួយចំនួនផងដែរ ។

ធនាគារអេអេនហ្សេតធ្លាប់បានប្រកាសប្រាប់អតិថិជន និងសាធារណជនថា ពួកគេនឹងជួបហានិភ័យ ប្រសិនបើការបោកប្រាស់នោះ បណ្តាលឲ្យមានចន្លោះប្រហោង។ ប្រភពដដែលបានប្រកាសថា ការលួចបន្លំតាមប្រព័ន្ធអេឡិចត្រូនិចគឺជនខិលខូល អាចប្រើប្រាស់អ៊ីនធើណែតមួយចំនួនផ្ញើអ៊ីម៉ែល ហើយអះអាងថាផ្ញើមកពីស្ថាប័នហិរញ្ញវត្ថុ ឬស្ថាប័នស្របច្បាប់ផ្សេងទៀត ដោយអ៊ីម៉ែលខ្លះបានបញ្ជាក់ប្រាប់អ្នកទទួលថា លេខសម្ងាត់ និងប្រព័ន្ធការពារ សុវត្ថិភាពរបស់គាត់ត្រូវធ្វើទំនើបកម្មដោយត្រូវចូលទៅក្នុងគេហទំព័រជាក់លាក់មួយ តែតាមពិតជាគេហទំព័រក្លែងក្លាយ។ គោលបំណងនៃ គេហទំព័រទាំងនេះគឺដើម្បីលួចយកទិន្នន័យចូលប្រើគណនីធនាគារតាមប្រព័ន្ធអ៊ីនធើណែត ដូចជា លេខកូដសម្ងាត់ លេខចុះឈ្មោះអតិថិជន លេខសម្ងាត់។

ប្រភពដដែល បានបន្តថា អ៊ីម៉ែលផ្សេងទៀតអាចមានសារអំពីសុវត្ថិភាព ឬឯកសារភ្ជាប់ណាមួយ ដើម្បីឱ្យលោកអ្នកទាញយក ប្រសិនបើអ៊ីម៉ែលផ្ញើមកពីប្រភពដែលលោកអ្នក មិនស្គាល់ច្បាស់ ឬក៏ប្រសិនបើលោកអ្នកមានការសង្ស័យ សូមលុបចោលជាបន្ទាន់ ហើយមិនត្រូវបើកឯកសារភ្ជាប់ ឬក៏បញ្ចូលកម្មវិធីណាមួយដែលបានផ្ញើមកឡើយ បើមិនដូច្នេះទេ គេអាចជ្រៀតចូលទិន្នន័យយើងបាន។ ប្រភពដដែលបានបន្តថា ពលរដ្ឋក៏ត្រូវមានការប្រយ័ត្នប្រយែងចំពោះការងារបោកបញ្ឆោតលួចប្រាក់នានាដែលមាន ផ្សាយតាមអ៊ីនធើណែត ដោយក្រុមហ៊ុនបរទេសក្លែងក្លាយជាច្រើនបានទាក់ទាញជនរងគ្រោះមិនឱ្យដឹងខ្លួនជាមុនដោយឱ្យធ្វើជា "ភ្នាក់ងារផ្ទេរប្រាក់" ក្នុងការលក់ទំនិញ និង សេវាកម្ម តាមវិធីផ្សេងៗដូចជា ការផ្សាយដំណឹងជ្រើសរើសបុគ្គលិកអ៊ីម៉ែលវិភាគទាន និងបណ្តាញជជែកតាមអ៊ីនធើណែត។

ប្រភពដដែលបានសង្កត់ធ្ងន់ថា "បុគ្គលិកដែលចង់ធ្វើការងារនេះ" ត្រូវបានស្នើសុំឱ្យប្រើគណនីផ្ទាល់ខ្លួន ដើម្បីធ្វើការផ្ទេរប្រាក់ទៅបរទេស។ ក្នុងករណីភាគច្រើន ជនរងគ្រោះត្រូវ បានណែនាំឱ្យផ្ញើប្រាក់ទាំងនោះទៅបរទេស ដោយសន្យាផ្តល់ជាកម្រៃជើងសារជាភាគរយនៃការផ្ទេរប្រាក់ តាមពិតនោះហើយគឺជាល្បិច ដែលយើងនឹងអនុញ្ញាតឲ្យគេយកទិន្នន័យហិរញ្ញវត្ថុយើងបាន ។

# ទិវាអង្គការសហប្រជាជាតិ ស្តីពីសប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនាពិភពលោកលើកទី៨

ក្រសួងធម្មការ និងសាសនាដោយមានការឧត្តម្ភពីអង្គការ DANMISSION បានរៀបចំទិវាអង្គការសហប្រជាជាតិ ស្តីពីសប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនាពិភពលោកលើកទី៨ ក្រោមប្រធានបទ "សន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍"។ នៅសណ្ឋាគារ ឡាវ៉ារេន រាជធានីភ្នំពេញ។

អង្គសិក្ខាសាលានេះប្រារព្ធឡើងនៅថ្ងៃទី២៧ កុម្ភៈ ២០១៨ ក្រោមអធិបតីភាពរបស់ឯកឧត្តម ផ្លោក ផន រដ្ឋលេខាធិការ ក្រសួងធម្មារ និងសាសនា ដោយមានអ្នកចូលរួមមកពីគ្រប់សាសនា ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមជាមួយអង្គការសង្គមស៊ីវិលមួយចំនួនដែលមានចរិតលក្ខណៈជាសាសនា។

យោងតាមសេចក្តីប្រកាសហេតុទិវានេះធ្វើឡើងដើម្បីផ្សព្វផ្សាយទិវាអង្គការសហប្រជាជាតិ ស្តីពីសប្តាហ៍សុខដុមនីយកម្មអន្តរជំនឿសាសនាពិភពលោកលើកទី៨ នៅព្រះរាជាណាចក្រកម្ពុជា។ ដើម្បីគាំទ្រផែនការយុទ្ធសាស្ត្រ និងកម្មវិធីសុខដុមនីយកម្មសាសនារបស់ក្រសួងធម្មការ និងសាសនា។ អនុវត្តតាមរដ្ឋធម្មនុញ្ញមាត្រា ៤៣ និងគោលដៅរបស់អង្គការសហប្រជាជាតិ។ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរសាសនា នៅព្រះរាជាណាចក្រកម្ពុជា។

ជាកិច្ចចាប់ផ្តើម លោកអ៊ឹន ដើជេនសិន ប្រធានអង្គការ Danmission ដែលជាភ្នាក់ងារបេសកកម្ម និងអភិវឌ្ឍន៍គ្រីស្តបរិស័ទមួយមកពីប្រទេសដាណាម៉ាក បានថ្លែងនៅក្នុងកិច្ចស្វាគមន៍ និងរំលឹកអំពីបព្វហេតុដើម នៃទិវាអង្គការសហប្រជាជាតិ ស្តីពីសប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនាពិភពលោក ដែលជ្រើសរើសយកសប្តាហ៍ដំបូង នៃខែកុម្ភៈដើម្បីប្រារព្ធទិវានេះ។

លោកផ្លោក ផន រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា បានថ្លែងនៅក្នុងពិធីបើកទិវានេះថា ទិវានេះពិតជាមានសារៈសំខាន់ក្នុងការរួមសាមគ្គីគ្នាជាអន្តរសាសនា ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស និងសហគមន៍ជាតិ-អន្តរជាតិ គ្មានអំពើហិង្សាគ្រប់ទម្រង់ និងរក្សាសន្តិភាព និងភាពសុខដុមរមនាសាសនា និងសហគមន៍ តាមរយៈអង្គសិក្ខាសាលាផ្សព្វផ្សាយទិវានេះ។

លោកបញ្ជាក់ថា សិក្ខាសាលាផ្សព្វផ្សាយនេះ នឹងផ្តល់ឱកាសសម្រាប់ផ្លាស់ប្តូរគំនិតទស្សនៈ និងបទពិសោធន៍ការងារទាំងអស់គ្នា ដើម្បីចូលរួមផ្សព្វផ្សាយអប់រំអំពីសន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍ ព្រមទាំងលើកស្ទួយការអភិវឌ្ឍសុខដុមរមនីយកម្មសាសនាឲ្យកាន់តែរីកចម្រើនថែមទៀត។ លោកក៏បាលលើកយកនូវកិច្ចខិតខំប្រឹងប្រែងរបស់រាជ្យរដ្ឋាភិបាលកម្ពុជាកន្លងមកដើម្បីទទួលបាននូវសុខដុមរមនីយកម្មរវាងសាសនា និងសាសនាផងដែរ។

ក្នុងអង្គសិក្ខាសានានៃទិវានេះក៏មានអ្នកជំនាញ មកពីអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ATC) ដើម្បីធ្វើបទបង្ហាញអំពីសន្តិភាព និងទំនាស់ឲ្យសិក្ខាកាមទាំងអស់យល់កាន់តែច្បាស់អំពីប្រភេទនៃទំនាស់ ការគ្រប់គ្រង និងដោះស្រាយទំនាស់ និងការអភិវឌ្ឍជានិរន្តរ៍ដោយផ្អែកលើគោលដៅ៣សំខាន់ៗគឺ រាជ្យរដ្ឋាភិបាល អ្នកជំនួញ និងសង្គមស៊ីវិល។

ក្នុងអង្គសិក្ខាសាលា សិក្ខាកាមក៏បានពិភាក្សាគ្នាជាក្រុម ដើម្បីផ្លាស់ប្តូរយោបល់ និងបទពិសោធន៍តាមគោលជំនឿសាសនារៀងៗខ្លួន។ ពេលបញ្ចប់អង្គសិក្ខាសាលា សិក្ខាកាមទាំងអស់បានសម្រេចសេចក្តីប្រកាសរួម និងប្តេជ្ញាចិត្ត រួមគ្នាផ្សព្វផ្សាយសេចក្តីសេចក្តីប្រកាសន៍នេះតាមសហគមន៍របស់ខ្លួនផ្ទាល់។ សេចក្តីប្រកាសមាន ១១ ចំនុចដូចជា៖ ១) សហគមន៍សាសនាចូលរួមផ្សព្វផ្សាយទិវាអង្គការសហប្រជាជាតិស្តីពី សប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនាជាមួយរាជរដ្ឋាភិបាលដល់សហគមន៍មូលដ្ឋានដើម្បីសន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍។ ២) សហគមន៍សាសនាប្តេជ្ញាចូលរួមអប់រំសន្តិភាព និងអភិវឌ្ឍន៍ជានិរន្តរ៍តាមសហគមន៍ សាសនា ដើម្បីកាត់បន្ថយភាពក្រីក្រ និងអំពើហិង្សាក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ ៣) រួមគ្នាប្តូងស្តួងរក្សាសន្តិភាព សុខដុមនីយកម្ម និងការអភិវឌ្ឍជានិរន្តរ៍ដល់ប្រទេសកម្ពុជា និងសាកលលោក។ ៤) ចូលរួមផ្សព្វផ្សាយអំពី ទិវាអង្គការសហប្រជាជាតិស្តីពី សប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនា ពិភពលោករៀងរាល់ឆ្នាំ។ ៥) ចូលរួមគាំទ្រទិវាអង្គការសហប្រជាជាតិស្តីពី សប្តាហ៍សុខដុមនីយកម្មអន្តរជំនឿ-សាសនា ពិភពលោក នៅក្នុងប្រទេស និងអន្តរជាតិ។ ៦) អប់រំ និងផ្សព្វផ្សាយអំពីសន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍ តាមបណ្តាញសារព័ត៌មាន និងតាមពិធីកម្មសាសនានានា។ ៧) ផ្សព្វផ្សាយគោលការណ៍សន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍ដោយគ្មានអំពើហិង្សាគ្រប់ទម្រង់។ ៨) រៀបចំបណ្តុះបណ្តាលក្រុមស្រាវជ្រាវ និងគ្រូបង្គោលប្រឹក្សាអំពីគោលការណ៍សន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍តាមសហគមន៍សាសនា។ ៩) ចូលរួមរៀបចំផែនការស្រាវជ្រាវ និងផ្សព្វផ្សាយអំពីគោលការណ៍សន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍ជាមួយក្រសួងធម្មការ និងសាសនា ដើម្បីផ្សព្វផ្សាយតាមសហគមន៍ជាតិ និងអន្តរជាតិ។ ១០) ដឹកនាំបង្កើតក្រុមការងារយុវជនចម្រុះសាសនាដើម្បីសន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍ចូលរួមការងារសង្គមជាមួយគ្នា។ ១១) គោរពតាមច្បាប់រដ្ឋ និងវិន័យសាសនានីមួយៗ៕

*ដោយ ដាលីស*



# ព្រះសហគមន៍កោះរកា សង់ផ្ទះជូនគ្រួសារមេម៉ាយក្រីក្រ ចំនួន២គ្រួសារ



ថតដោយ សុធីរិទ្ធ

ផ្ទះឈើប្រក់សង្កសីចំនួន២ខ្នង ដែលមានទំហំ៥ គុណ៦ និងទំហំ៤ គុណ ៥ បានសាងសង់ រួចរាល់និងប្រគល់ ជូនគ្រួសារស្ត្រីមេម៉ាយក្រីក្រចំនួន២គ្រួសារ ដែលមានជីវភាពខ្វះខាត គ្មានទីជំរក នៅក្នុងភូមិកោះរកា និងភូមិរលៀក ដែលជាអំណោយរបស់ក្រុមស្មគ្រចិត្តបារាំង តាមរយៈព្រះសហគមន៍កាតូលិកកោះរកា។

លោកផាន បូរី ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកកោះរកា នៃភូមិភាគកំពង់ចាម បានមានប្រសាសន៍ឱ្យដឹងថា ព្រះសហគមន៍ជ្រើសរើស គ្រួសារស្ត្រីមេម៉ាយទាំងពីរគ្រួសារនេះ ដោយគេខ្វះខាតនិងកូនច្រើន ហើយគ្មានទីជំរក។

លោកបន្តថា ផ្ទះទាំងពីរនេះ ជាការជួយឧបត្ថម្ភគាំទ្រថវិការ និងកម្លាំងកាយចិត្ត សាងសង់ដោយផ្ទាល់ ពីក្រុមស្ម័គ្រចិត្តជនជាតិបារាំងចំនួន១០នាក់។ តាមការគ្រោងទុក ការសាងសង់ផ្ទះនីមួយៗត្រូវប្រើរយៈពេលសាងសង់ចំនួន១០ថ្ងៃ និងចំណាយថវិការសម្រាប់ ផ្ទះមួយៗចំនួន១៥០០ដូល្លារ ។

លោកបូជាចារ្យផាន បូរី បន្ថែមថា ជំនួយទាំងនេះ ពិតជាមានតម្លៃដ៏វិសេសវិសាលសម្រាប់គ្រួសារទាំងពីរនេះ ហើយជាការចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងសង្គម។ ផ្ទះនេះ ក៏ជាការបញ្ជាក់ពីការបរិច្ចាគ និងផ្តល់ក្តីសង្ឃឹមថ្មីដល់គ្រួសារស្ត្រីមេម៉ាយនេះផងដែរ ។

គួរបញ្ជាក់ថា ព្រះសហគមន៍កោះរកា នៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ក្រៅពីការជួយលើផ្នែកមនុស្សធម៌ និងការសម្តែងធម៌មេត្តាករុណាចំពោះអ្នកក្រីក្រ។ ព្រះសហគមន ក៏មានគម្រោងផ្សេងៗទៀត ដូចជា វិស័យសុខាភិបាល និង វិស័យអប់រំទូទៅ ដោយជួយទៅដល់យុវជនយុវនារី ឱ្យពួកគេបានបន្តការសិក្សាថ្នាក់វិទ្យាល័យ ជួយឱ្យពួកគេមានចំណេះដឹង ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម ទៅថ្ងៃអនាគត៕

ដោយ ឡុងសម្ផស្ស

# មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា រៀបចំប្រកួតកីឡាស្ត្រី ដើម្បីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ

មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា បានរៀបចំការប្រកួតកីឡាស្ត្រី ជាមិត្តភាព រវាងនិស្សិតគ្រប់ឆ្នាំក្នុងមណ្ឌលជាមួយអតីតនិស្សិត ជាស្ត្រី ដែលបានស្នាក់នៅក្នុងមណ្ឌនិស្សិតកាតូលិកកម្ពុជា ដើម្បីចូលរួមអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ ថ្ងៃទី៨ ខែមីនា លើកទី១០៧ ដែលបានប្រព្រឹត្តទៅក្នុងមណ្ឌលនិស្សិតផ្ទាល់ នៅសង្កាត់បឹងត្របែក រាជធានី ។

កញ្ញាស្រី ប៉ុញ្ញាកា ប្រធានមណ្ឌលកាតូលិកកម្ពុជា បានឲ្យដឹងថាមណ្ឌលនិស្សិតបានរៀបចំកម្មវិធីនេះឡើង ក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនងឱ្យកាន់តែមានភាពជិតស្និទ្ធរវាងមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា ជាមួយនឹងមណ្ឌលនិស្សិតផ្សេងៗទៀតនៃ ព្រះសហគមន៍កាតូលិកនៅរាជធានីភ្នំពេញ ជាពិសេសរវាងនិស្សិតបច្ចុប្បន្ន និងអតីតនិស្សិត។ កញ្ញាបានបញ្ជាក់បន្ថែមថា កម្មវិធីនេះក៏ធ្វើឡើងដើម្បីរួមគ្នាចែករំលែកនូវអំណរសប្បាយជាមួយគ្នា ដោយមិនប្រកាន់វ័យ ឬតំបន់ណាឡើយ។

កញ្ញាបុញ្ញាកា បានឲ្យដឹងទៀតថា មណ្ឌលតែងប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិជារៀងរាល់ឆ្នាំ។ នៅថ្ងៃទី៨ មីនានេះ មណ្ឌលបានធ្វើកម្មវីធីសម្រាប់ស្រីៗនៅក្នុងមណ្ឌល ឱ្យនិស្សិតស្រីៗមានពេលវេលាសម្រាកពេញមួយថ្ងៃ ដោយអត់ធ្វើម្ហូប លាងចាន ជូតផ្ទះនិងការងារផ្សេងៗទេ ដោយមាននិស្សិតប្រុសជាអ្នករ៉ាប់រងធ្វើកិច្ចនេះទាំងស្រុង។ ដោយឡែកនៅឆ្នាំនេះមណ្ឌលបានរៀបចំកម្មវិធីប្រកួតវាយសីសម្រាប់ស្រីៗ រវាងមណ្ឌលនិស្សិត និងមណ្ឌលផ្សេងៗ ជាពិសេសអតីតនិស្សិត។ បន្ទាប់មកយើងមានកម្មវិធីជប់លៀងអបអរសាទរទិវានារីអន្តរជាតិរួមគ្នានៅពេលល្ងាច។ ជាងនេះទៅទៀតកញ្ញាប្រធានមណ្ឌល បានបង្ហាញផងដែរអំពីការចូលរួមលើកកំពស់ស្ត្រីតាមរយៈជំនឿរបស់ព្រះសហគមន៍ ដែលបុរស និងស្ត្រីមានតម្លៃស្មើគ្នា។

យុវនិស្សិត ហ៊្ស ចិន្តា មកពីខេត្តព្រៃវែង បានឲ្យដឹងថា កម្មវិធីនេះពិតជាមានសារៈសំខាន់ ចំពោះខ្ញុំក៏ដូចជានិស្សិតស្រីផ្សេងៗ ដើម្បីបង្ហាញពីសមត្ថភាពផ្សេងៗរបស់ស្ត្រីទាំង វិស័យកីឡាក៏ដូចជាវិស័យដទៃទៀត ដោយមិនមែនត្រឹមតែជាស្ត្រីមេផ្ទះប៉ុណ្ណោះទេ។ ចិតន្តាបន្តថា ម៉្យាងវិញទៀតថ្ងៃនេះ មណ្ឌលបានផ្តល់ឱកាសដើម្បីបង្កើតទំនាក់-ទំនងជាមួយបងៗអតីតនិស្សិត ក៏ដូចជានិស្សិតនៅកន្លែងផ្សេងទៀត ដោយអាចយកថ្ងៃដែលឈប់សម្រាកនេះមកធ្វើកិច្ច-ការដែលមានប្រយោជន៍។ និស្សិតវិស្វកម្មវិទ្យាសាស្ត្រឆ្នាំទី២រូបនេះ បានកត់សម្គាល់ឃើញថា មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជាបានយកចិត្តទុកដាក់ចំពោះនិស្សិតនារីជាពិសេសចំពោះសុវត្ថិភាព ដោយមានការបែងចែកការស្នាក់នៅ និងយកចិត្តទុកដាក់ចំពោះសុខមាលភាពរបស់និស្សិតហើយចំណែកនិស្សិតប្រុសៗនៅទីនេះក៏បានផ្តល់នូវតម្លៃដល់និស្សិតស្រីតាមរយៈពាក្យសម្តីនិងកាយវិការ ព្រោះបានទទួលការអប់រំពីមណ្ឌលផ្ទាល់តែម្តង។

គួរបញ្ជាក់ថា មណ្ឌលនិស្សិតព្រះសហ-គមន៍កាតូលិកកម្ពុជា បានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ ដើម្បីជួយ និងផ្តល់ឱកាសដល់និស្សិតក្រីក្រពីខេត្តឆ្ងាយៗ បានស្នាក់នៅទទួលការសិក្សាបន្តថ្នាក់ឧត្តមសិក្សានៅរាជធានីភ្នំពេញ ជាពិសេសយុវនារី ជានិស្សិត ដែលមកពីបណ្តាខេត្ត ដោយផ្តល់អាហារូបករណ៍ច្រើនកន្លែងជាងបុរស។ កីឡាក៏ជាផ្នែកមួយ ដែលមណ្ឌលយកចិត្តទុកដាក់ ស្របពេលដែលមណ្ឌលបានផ្តល់ការអប់រំល្អៗអំពីសេចក្តីស្រឡាញ់សិទ្ធិក្នុងការចូលរួមនៅគ្រប់សកម្មភាពដែលពួកគេអាចចូលរួមបាន រួមទាំងការថែរក្សានូវតម្លៃនិងសេចក្តីថ្លៃថ្នូរក្នុងជីវិតរស់នៅដោយផ្សារភ្ជាប់ជាមួយនឹងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរផងដែរ៕

ដោយ ដាលីស



# ភូមិភាគបាត់ដំបងទទួលបេក្ខជនបេក្ខនារី៤៩ នាក់ ក្នុងពិធីត្រាស់ហៅយ៉ាងឱឡារិក

បេក្ខជនបេក្ខនារីចំនួន៤៩ នាក់ អញ្ជើញមកពីព្រះសហគមន៍នានា ក្នុងព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានទទួលការត្រាស់ហៅយ៉ាងឱឡារិក (ជំហានទី២) ពីលោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង។ ពិធីនេះបានប្រារព្ធកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្រុងបាត់ដំបង ដោយមានការចូលរួមពីលោកបូជាចារ្យ គ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

មានប្រសាសន៍ក្នុងធម្មទេសនា លោកតូតែត បានេណាល់ តំណាងពេញសិទ្ធិរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង និងជាបូជាចារ្យទទួលខុសត្រូវនៅទឹកដីអង្គរ ខេត្តសៀមរាបបានមានប្រសាសន៍ថា នៅថ្ងៃនេះយើងជួបជុំគ្នាដើម្បីស្វាគមន៍ និងលើកទឹកចិត្តដល់បងប្អូន ជាមនុស្សពេញវ័យ ដែលហៀបទទួលពិធីជ្រមុជទឹកនៅក្នុងឱកាសបុណ្យចម្លងខាងមុខនៅក្នុងព្រះសហគមន៍របស់យើង។

លោកបន្តថា សម្រាប់យើងម្នាក់ៗ ដែលជាអ្នកដើរតាមព្រះយេស៊ូ នៅក្នុងរដូវ៤០ថ្ងៃនេះ ត្រូវយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ដោយអនុវត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។ ព្រះជាម្ចាស់ព្រះអង្គមិនត្រូវការសំភារៈអ្វីទេ សម្រាប់យើងយកមកថ្វាយព្រះអង្គ គឺត្រូវការដង្វាយ ដែលជាចិត្តបរិសុទ្ធរបស់យើងម្នាក់ៗ ថ្វាយទៅព្រះអង្គ។ លោកថា លោកអភិបាលបានណែនាំបងប្អូន សូមឱ្យស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយទំនាក់ទំនងផ្ទាល់ជាមួយព្រះអង្គយ៉ាងជិតស្និទ ដោយមានចិត្តដ៏បរិសុទ្ធ មិនត្រឹមតែជាការលំអរខាងក្រៅនោះទេ ប៉ុន្តែសូមរៀបចំចិត្តឱ្យបានបរិសុទ្ធវិញ។

ក្នុងពេលនោះដែរលោកក៏បានមានប្រសាសន៍ទៅកាន់បងប្អូនជាបេក្ខជន បេក្ខនារី ដែលទទួលការត្រាស់ហៅយ៉ាងឱឡារិកពីលោកអភិបាលព្រះសហគមន៍ គឺលោកអភិបាលត្រាស់ហៅតាមឈ្មោះបងប្អូនផ្ទាល់ម្នាក់ៗ។ លោកថានេះគឺមិនមែនលោកអភិបាលនោះទេគឺព្រះអង្គផ្ទាល់ជាអ្នក ត្រាស់ហៅបងប្អូនឲ្យបានទៅជា សាវ័ករបស់ព្រះយេស៊ូ ទៅជាបុត្រធីតារបស់ព្រះអង្គ។ ត្រាស់ហៅឲ្យចូលរួមក្នុងព្រះកាយតែមួយ ព្រមទាំងឱ្យបងប្អូនចូលរួមជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់តាមឈ្មោះម្នាក់ផ្ទាល់។ ហេតុនេះត្រូវស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ និអនុវត្តន៍តាមព្រះបន្ទូលរបស់ព្រះអង្គ។

អង្គុយលើរទេះជនពិការ បេក្ខនារីទទួលជំហានទី២ កញ្ញាឃុត វន្នី បានឱ្យដឹងថា កញ្ញាសុខចិត្តទទួលការអប់រំជំនឿតាមព្រះសហគមន៍កាតូលិក និងដើរតាមព្រះយេស៊ូគ្រីស្ត ក៏ព្រោះតែការស្រឡាញ់ និងជាការពេញចិត្តដោយខ្លួនឯង ហើយទៅថ្ងៃខាងមុខកញ្ញា និងថែរក្សាជំនឿរបស់ខ្លួន ដែលជាគ្រីស្តបរិស័ទម្នាក់ដ៏ល្អម្នាក់ និងហ៊ានប្រកាសថា ខ្លួនជាគ្រីស្តបរិស័ទនៅចំពោះមុខអ្នកឯទៀតៗ ។

បេក្ខជនទទួលជំហានទី២ម្នាក់ទៀត មកពីព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេ ស្វាយសុីសុផុន ប្អូនប្រុស សុខ ពិសិដ្ឋ អាយុ១៦ ឆ្នាំ បានឱ្យដឹងថា គ្រប់ពេលលោកបូជាចារ្យថ្វាយអភិបូជា និងអត្ថាធិប្បាយព្រះគម្ពីរជួយឱ្យប្អូនជាប់ចិត្តនិងព្រះបន្ទូលព្រះជាម្ចាស់ សម្រាប់ណែនាំជីវិតរបស់ប្អូន ក្នុងការដើរតាមព្រះយេស៊ូនាពេលនេះ។

សៀ សៀក ជាគ្រូអប់រំជំនឿ នៃព្រះសហគមន៍តាហែន បានចាប់អារម្មណ៍ថា នាងមានអំណរសប្បាយ ដែលបានឃើញផលផ្លែរបស់ព្រះសហគមន៍។ ខណៈព្រះសហគមន៍តាហែនមានបងប្អូនចំនួន ៦ នាក់ បានទទួលជំហានទី២នៅថ្ងៃនេះ ហើយ និងត្រូវទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងខាងមុខ ។

អ្នកគ្រូ សៀកបន្តថា អ្វីៗដែលយើងបានទទួលនៅថ្ងៃនេះ គឺបានបង្ហាញថា ព្រះសហគមន៍ពិតជាមានជីវិតដ៏រស់រវើក។

ចំណែកលោករេត រស្មី គ្រូអប់ជំនឿពីតាហែនដែរនោះ បាននិយាយទាំងអំណរថា "មានអំណរណាស់ ដោយមានបងប្អូន៦នាក់បានទទួល បន្តជំនឿពីខ្ញុំ។ ខ្ញុំនឹងរួមដំណើរជាមួយគាត់បន្តទៀត ដើម្បីជួយឲ្យគាត់រីកចម្រើនក្នុងជំនឿ និងជួយឲ្យព្រះសហគមន៍រីកចម្រើនផងដែរ"។

លោកអភិបាល អែនរីគេ ហ្វីការេដូ ក្នុងនាមអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងលោកមានសេចក្តីរីករាយណាស់។ លោកថា រីករាយដោយសារបងប្អូនចេះស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចេះប្រែចិត្តគំនិត ចេះអធិដ្ឋាន និងមានចិត្តចង់ដើរតាមព្រះយេស៊ូ។ ម្យ៉ាងទៀតគ្រូអប់រំជំនឿក៏ជាកម្លាំងសម្រាប់លោកដែរ គឺគេចែករំលែកពេលវេលា ជីវិត ជំនឿ និងអ្វីៗដែលមានក្នុងដួងចិត្ត ពេលនេះមានលទ្ធផលហើយ។ ជាងនេះទៅទៀតគឺអំណរសប្បាយដោយសារព្រះសហគមន៍ជាប់ជាមួយបងប្អូនក្នុងភូមិ មានតែអំណរមកពីព្រះជាម្ចាស់។ ព្រះសហគមន៍មានព្រះពរពិសេសមកពីព្រះជាម្ចាស់។ បងប្អូនមានចិត្តតែមួយ និងធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

នៅក្នុងឱកាសរាត្រីបុណ្យចម្លងខាងមុខនេះ មានបងប្អូនជាមនុស្សពេញវ័យរៀបចំខ្លួនទទួលពិធីជ្រមុជទឹកនៅតាមព្រះសហគមន៍កាតូលិកក្នុងភូមិភាគទាំងបី មានចំនួនប្រមាណជា១៥២នាក់ ក្នុងនោះព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានចំនួន៦៧នាក់ ភូមិភាគបាត់ដំបង មានចំនួន៤៩នាក់ និងភូមិភាគកំពង់ចាមមានចំនួន៣៦ នាក់ ៕



ថតដោយ រិទ្ធិរដ្ឋ

# អធិដ្ឋាន២៤ម៉ោងថ្វាយព្រះអម្ចាស់នៅក្នុងភូមិភាគភ្នំពេញ

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំឲ្យមានកម្មវិធីអធិដ្ឋាន ២៤ ម៉ោងថ្វាយព្រះអម្ចាស់ កាលពីថ្ងៃទី១០ និង១១ ខែមីនា ឆ្នាំ២០១៨ នៅតាមព្រះសហគមន៍នីមួយៗ តាមមណ្ឌលសកម្មភាពទាំង៩។ ពិធីអធិដ្ឋាននេះប្រព្រឹត្តទៅស្របតាមសេចក្ដីអញ្ជើញរបស់សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូដើម្បីអធិដ្ឋានរួមគ្នាដោយនមស្ការនៅមុខព្រះកាយព្រះគ្រីស្ដ និងទទួលអគ្គសញ្ញាលើកលែងទោស នៅតាមព្រះសហគមន៍នានាក្នុងពិភពលោកទាំងមូល។

នៅក្នុងសារលិខិតសម្រាប់រដូវ៤០ថ្ងៃ សម្ដេចប៉ាបក៏បានអញ្ជើញព្រះសហគមន៍ទាំងអស់ប្រារព្ធពិធីអធិដ្ឋានគឺ "២៤ម៉ោងថ្វាយព្រះអម្ចាស់" ដើម្បីដាស់តឿនម្នាក់ៗឲ្យវិលមករកព្រះជាម្ចាស់វិញ ដោយទទួលអគ្គសញ្ញាលើកលែងទោស និងនមស្ការព្រះកាយ។

ក្នុងឆ្នាំ២០១៨ "ពិធី២៤ម៉ោងថ្វាយព្រះអម្ចាស់" បានប្រព្រឹត្តទៅពីថ្ងៃសុក្រទី៩ ខែមីនា ដល់ថ្ងៃសៅរ៍ ទី១០ ខែមីនា ឆ្នាំ២០១៨ ដោយនឹកដល់ព្រះបន្ទូលតាមទំនុកតម្កើង១៣០: ៤ "ព្រះអង្គតែងតែអត់ទោសឲ្យយើងខ្ញុំជានិច្ច"។


ថតដោយ អន ហំ

ពេលនោះដែរលោកអភិបាលអូលីវីយេក៏បានអធិដ្ឋាន និងជូនពរបងប្អូនទាំងអស់នាល្ងាចថ្ងៃសៅរ៍ ទី១០ ខែមីនានេះថា "ខ្ញុំបានប្រារព្ធពិធីបុណ្យអភិបូជា បើកកម្មវិធីនៅភ្នំពេញថ្មីហើយបានទូលសុំអង្វរព្រះជាម្ចាស់ ដើម្បីប្រទានពរដល់បងប្អូនទាំងអស់ក្នុងឱកាសដ៏ពិសេសនៃការអធិដ្ឋាននមស្ការព្រះកាយព្រះគ្រីស្ដ ក្នុងពេលតែមួយរួមគ្នានៅក្នុងភូមិភាគភ្នំពេញ ក៏ដូចជារួមជាមួយសម្ដេចប៉ាប និងព្រះសហគមន៍សាកលទាំងមូលផងដែរ"។

លោកបន្តថា "សូមឲ្យការអធិដ្ឋាននេះពោរពេញដោយសន្តិភាព អំណរសប្បាយ និងពោរពេញដោយសេចក្ដីស្រឡាញ់ នៅក្នុងក្រុមគ្រួសារនិងសម្រាប់ការត្រាស់ហៅផងដែរ!"។

*ដោយ ដាលីស*

# បុណ្យរំឭកខួបនៃមរណៈភាពរបស់លោកបូជាចារ្យ ត្រឿង ប៊ូយៀប


ថតដោយ លី សុវណ្ណា

ព្រះសហគមន៍កាតូលិក មណ្ឌលសកម្មភាពមេគង្គ នៃភូមិភាគភ្នំពេញបានរៀបចំពិធីបុណ្យរំឭកដល់លោកបូជាចារ្យហ្វ្រង់ស៊ីស្កូត្រឿងប៊ូយៀប ដែលបានលះបង់ជីវិតដើម្បីការពារគ្រីស្តបរិស័ទ។ ពិធីនេះបានប្រព្រឹត្តឡើងយ៉ាងឱឡារិកក្រោមអធិបតីភាពលោកអភិបាលអូលីវីយេដោយមានគ្រីស្តបរិស័ទរាប់ពាន់អ្នកចូលរួម កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ នៅព្រះវិហារព្រះបេះដូងព្រះយេស៊ូ (ផ្លូវត្រី) ក្នុងភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល។

ក្នុងឱកាសនេះដែរលោកអភិបាលបានណែនាំគ្រីស្តបរិស័ទទាំងអស់ដោយលើកយកគំរូនៃការខិតខំបម្រើព្រះជាម្ចាស់ បម្រើព្រះសហគមន៍ អស់ពីកម្លាំងចិត្ត កម្លាំងកាយ និងប្រាជ្ញាស្មារតី របស់លោកបូជាចារ្យប៊ូហៀប។ លោកបន្តថា ថ្ងៃនេះយើងបានមើលឃើញជាក់ស្ដែងពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់តាមរយៈលោកប៊ូយៀប ដែលបានបម្រើព្រះជាម្ចាស់រហូតបាត់បង់ជីវិត។

លោកអូលីវីយេ បានដាស់តឿនគ្រីស្តបរិស័ទឲ្យមើលនៅក្នុងសម័យព្រះយេស៊ូមានមនុស្សជាច្រើនទៅជួប និងប៉ះព្រះយេស៊ូដោយស្រេកឃ្លានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ លោកបញ្ជាក់ថា អ្នកដែលមកជួបព្រះយេស៊ូ ភាគច្រើនជាអ្នកក្រីក្រ អ្នកគ្មានទីពឹង អ្នកជំងឺ ស្ត្រីមេម៉ាយ និងអស់អ្នកដែលមានបាប។ លោកអភិបាលមានប្រសាសន៍ទៀតថា ថ្ងៃនេះយើងក៏ដូចគ្នាដែរ គឺមកដើម្បីជួបព្រះយេស៊ូ ព្រោះទ្រង់ជាព្រះបុត្រាដែលយាងមកមិនមែនដើម្បីដាក់ទោសមនុស្សលោកទេ តែយាងមក ដើម្បីសង្គ្រោះមនុស្សឲ្យមានជីវិតថ្មី។

លោកអភិបាលបានផ្ដាំផ្ញើទៀតថា ទ្រព្យសម្បត្តិរបស់យើងពិត មិនមែនជាមាសប្រាក់ និងលុយនោះទេ គឺសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលទ្រង់បានប្រទានមកឲ្យយើង។ លោកបញ្ជាក់ទៀតថា សេចក្ដីស្រឡាញ់ សេចក្ដីពិតដែលព្រះយេស៊ូឲ្យយើង គឺសេរីភាពដ៏ពិតប្រាកដដែលជាតម្លៃដ៏ខ្ពស់បំផុត។ លោកអភិបាលភូមិភាគភ្នំពេញស្នើឲ្យគ្រីស្តបរិស័ទអធិដ្ឋានបន្ថែមទៀតដើម្បីឲ្យយើងប្រព្រឹត្តអំពើល្អតាមព្រះបន្ទូលរបស់ព្រះយេស៊ូរៀងៗខ្លួន និងដើម្បីបម្រើព្រះសហគមន៍ដូចលោកបូជាចារ្យ ប៊ូយៀបផងដែរ។

លោក សោ វ៉ាន់ណា គណៈកម្មកាព្រះសហគមន៍ផ្លូវត្រី បានរៀបរាប់ ពីការអស្ចារ្យ លោកប៊ូយៀបបានជួយប្រជាជនដែលមកអុជធូប លោកបញ្ជាក់ថា ពីមុនខ្ញុំក្រ តែក្រោយពីអុជធូបសុំដោយចិត្តស្មោះមកខ្ញុំបានរកស៊ីមានបាន ហើយអ្នកភូមិនេះពីមុនក៏ក្រលំបាកដែរ តែឥលូវមានលទ្ធភាពអាចទិញឡានដឹកស្វាយបានទៀតផង។ លោកបន្តថា ក្រៅពីសុំជំនួយក្នុងការរកស៊ី លោកក៏ធ្លាប់សុំលោកបូជាចារ្យយៀបឲ្យជួយព្យាបាលជំងឺផងដែរ ហើយទទួលបានលទ្ធផលប្រាកដមែន។

លោក ហ្វ្រង់ស៊ីស្កូ ត្រឿងប៊ូ យៀប កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៩៧ នៅខេត្តអាងយ៉ាង។ នៅឆ្នាំ១៩២៤ លោកត្រូវបានតែងតាំងជាបូជាចារ្យ នៅភ្នំពេញក្នុងសម័យលោកអភិបាល Valentin Herrgotte ។ ឆ្នាំ១៩២៤ ដល់១៩២៥ លោកបូជាចារ្យ ត្រឿង ប៊ូយៀប ត្រូវបានចាត់ឲ្យបំពេញបេសកម្មជាបូជាចារ្យជំនួយនៅព្រះសហគមន៍ផ្លូវត្រី។ លោកបានស្លាប់ដោយសារគេ កាត់ក នៅ តាំកសី ប្រទេសវៀតណាមនាថ្ងៃទី១២ មីនា ១៩៤៦។ ក្បាលរបស់ លោក ត្រឿង ប៊ូយៀប គឺមិនមានភាពស្អុយរលួយឡើយ នេះជាអំណោយទានមួយរបស់ព្រះជាម្ចាស់ប្រទានពរឲ្យលោកព្រោះជំនឿរបស់គាត់ពិតជារឹងមាំណាស់ដោយ ហ៊ាន បូជាជីវិតដើម្បីគ្រីស្តបរិស័ទទៀតផង។

បច្ចុប្បន្នមានមនុស្សជាច្រើនទាំងក្នុងនិងក្រៅប្រទេសទាំងគ្រីស្តបរិស័ទ និងអ្នកដែលមានជំនឿលើសាសនាដទៃទៀតបានមកព្រះសហគមន៍ផ្លូវត្រី ដើម្បីអុជធូមសូមសេចក្ដីសុខតាមតម្រូវការរបស់ខ្លួនជាពិសេសគឺសម្រាប់មុខជំនួញ។

*ដោយ ដាលីស*

# អង្គការការីតាសកម្ពុជា ប្រារព្ធទិវានៃការអធិដ្ឋាន និងការយល់ដឹងប្រឆាំង នឹងការជួញដូរមនុស្ស



ថតដោយ សម្ផស្ស

អង្គការការីតាសកម្ពុជា បានប្រារព្ធពិធីអធិដ្ឋាន នៅថ្ងៃទិវាសាកល នៃការអធិដ្ឋាន និងយល់ដឹង ប្រឆាំងការជួញដូរមនុស្ស នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨ នៅក្នុងស្នាក់ការរបស់ខ្លួននាក្រុងភ្នំពេញ។

កម្មវិធីនេះប្រព្រឹត្តទៅឡើងក្រោមអធិបតីភាពលោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងជាប្រធានក្រុមប្រឹក្សាអង្គការការីតាស់កម្ពុជ និងលោកបូជាចារ្យសួន ហង្សលី ជាតំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ រួមជាមួយថ្នាក់ដឹកនាំ បុគ្គលិក អង្គការការីតាស់កម្ពុជា ព្រមទាំងបងប្អូនគ្រីស្ត-បរិស័ទជាច្រើនរូប។

កញ្ញាសុភក្រ្ត មន្ត្រីអង្គការការីតាស់ ផ្នែកប្រឆាំងការជួញដូរមនុស្ស បានបញ្ជាក់ថា កម្មវិធីនៅថ្ងៃនេះ គឺជាការអធិដ្ឋានសម្រាប់ជនរងគ្រោះនានា ពីការជួញដូរ និងរំលោភបំពាន ព្រមទាងជាការបង្ហាញឱ្យឃើញ និងចូលរួមលើកទឹកចិត្តដល់ជនរងគ្រោះ ដើម្បីឱ្យពួកគេបន្តជីវិតរស់នៅក្នុងក្រុមគ្រួសារ ហើយនិងក៏ជាសារមួយចូលរួមបង្កើននូវការយល់ដឹងអំពីបញ្ហានៃការជួញដូរមនុស្សនេះផងដែរ។ កញ្ញាបន្តថា តាមរយៈការអធិដ្ឋានរបស់យើងនៅថ្ងៃនេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីបទពិសោធន៍របស់អ្នកដែលរងទុក្ខលំបាកទាំងនោះទេ គឺបានបង្ហាញឱ្យឃើញបញ្ហានេះ ដែលប៉ះពាល់ចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយថែមទាំងផ្តល់នូវការលើកទឹកចិត្តដល់អ្នករស់រានមានជីវិតទៀតផង។

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោកអេនរីគេ ហ្វីការេដូ បានមានប្រសាសន៍ថា យោងតាមប្រសាសន៍របស់សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ ព្រះសហគមន៍កាតូលិកសកលបានរៀបចំកម្មវិធីអធិដ្ឋានសម្រាប់ជនរងគ្រោះដោយសារការជួញដូរមនុស្ស នេះសម្តេចប៉ាបចង់ឱ្យយើងអធិដ្ឋាន ចង់ឱ្យយើងចូលរួមទាំងអស់គ្នា ដើម្បីឱ្យយើងស្តែងចេញជាសកម្មភាព ដើម្បីឱ្យយើងការពារថែរក្សាអ្នកតូចតាច ដោយគោរពតម្លៃរបស់មនុស្សដូចគ្នា។

ជាមួយគ្នានោះលោកគឹម រតនា នាយកប្រតបត្តិអង្គការការីតាស់កម្ពុជា បានចាប់អារម្មណ៍ថា ការអធិដ្ឋានជួយយើងឱ្យមានពន្លឺកាន់តែច្បាស់ និងមានកម្លាំងបន្ថែមទៀត ដើម្បីចូលរួមយ៉ាងសកម្ម ដើម្បីកាត់បន្ថយ ព្រមទាំងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនេះ។

លោកបន្តថា ជាមួយគ្នានេះយើងក៏ធ្វើសកម្មភាពជួយអប់រំដល់ប្រជាពលរដ្ឋដើម្បីឆ្វេងយល់អំពីអំពើនៃការជួញដូរមនុស្ស។ យើងជួយជនរងគ្រោះ ដែលកំពុងតែរងគ្រោះ ដើម្បីឱ្យគេមានទិសដៅនៃជីវិតបានល្អប្រសើរឡើង ដោយមានសេចក្តីសង្ឃឹមក្នុងការរស់នៅក្នុងក្រុមគ្រួសារ។

ក្រុមប្រឹក្សាសម្រាប់យុត្តិធម៌និងសន្តិភាព និងសហប្រតិបត្តិការអន្តរជាតិរបស់បុរី-វ៉ាទីកង់ បានកំណត់យកថ្ងៃទី០៨ ខែកុម្ភៈ ជាថ្ងៃអធិដ្ឋានប្រចាំឆ្នាំ សម្រាប់ការយល់ដឹងប្រឆាំងនឹងការជួញដូរមនុស្សជាសកល។

ថ្ងៃទី៨ ខែកុម្ភៈ នេះក៏ជាថ្ងៃបុណ្យគោរពសន្តី យ៉ូសែហ្វីន បាឃីតា Josephine Bakhita ដែលជាឧបការីសម្រាប់ជនរង-គ្រោះដោយការរំលោភបំពាន និងការជួញដូរ។ កុមារី យ៉ូសែហ្វីន បាឃីតា ត្រូវបានគេចាប់ពង្រត់ និងលក់បន្តបន្ទាប់គ្នា ឱ្យធ្វើជាទាសករនៅក្នុងប្រទេសស៊ូដង់ និងអ៊ីតាលី។ ក្រោយមក Josephine Bakhita ត្រូវបានដោះលែង។ នាងបានក្លាយជាដូនជីកាតូលិក ហើយបានឧទ្ទិសជីវិតរបស់នាង ដើម្បីចែករំលែកនូវបទពិសោធន៍អំពីសេចក្តីបញ្ជាក់អំពីជីវិតទាសភាព អំពីការចាកចេញពីទាសភាព ការលួងលោមប្រជាជនក្រីក្រ និងអ្នកដែលរងទុក្ខវេទនា។ ព្រះសហគមន៍កាតូលិកបានប្រកាសទទួលស្គាល់ យ៉ូសែហ្វីន បាឃីតា ជាសន្តីនៅក្នុងឆ្នាំ២០០០។

បើតាមសមាគមវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យាសហរដ្ឋអាមេរិក បានឱ្យដឹងថា ជនរងគ្រោះដោយសារការជួញដូរមនុស្សទទួលរងនូវជម្ងឺមួយចំនួនដែលជះឥទ្ធិពលដល់ប្រព័ន្ធខួរក្បាល ជាពិសេសគឺមានជំងឺបាក់ស្បាត ដែលអាចជះឥទ្ធិពលអវិជ្ជមាន ឬអាចមានផលអាក្រក់ ប៉ះពាល់ដល់សារធាតុគីមី និងប្រព័ន្ធប្រសាទក្នុងខួរក្បាល។ រោគសញ្ញានៃជម្ងឺបាក់ស្បាតលេចចេញនូវរូបភាព ឬនឹកឃើញអតីតកាលធ្វើឱ្យរន្ធត់ភ្លាមៗក្នុងខួរក្បាល ការយល់សុបិន្តអាក្រក់ គេងមិនលក់ គេងតិច ការគិតអវិជ្ជមាន ការភ័យខ្លាច ឆាប់ខឹងខ្មាស់អៀន អាម៉ាស់ អាកប្បកិរិយា ឡេះឡះ (មិនប្រុងប្រយ័ត្ន) ឆេវឆាវ និងមួរម៉ៅជាដើម។ ការប៉ះទង្គិចផ្លូវចិត្តឱ្យផ្លាស់ប្តូរជីវ-សាស្ត្ររបស់ប្រព័ន្ធប្រសាទរបស់បុគ្គលម្នាក់ៗ ទៅជាប្រព័ន្ធនៃភាពតានតឹង។ នេះអាចធ្វើឱ្យបុគ្គលម្នាក់នោះតែងតែស្ថិតក្នុងស្ថានភាពមមើមមាយ ហោះហើរ ឬជាប់គាំង។ បុគ្គលដែលមានការប៉ះទង្គិចផ្លូវចិត្តបង្ហាញការផ្លាស់ប្តូរលើកំរិតអ័រម៉ូន ដែលពាក់ព័ន្ធ និងមានភាពតានតឹង ដែលស្រដៀងនឹងកំរិតនៃការផ្លាស់ប្តូរអ័រម៉ូនរបស់ទាហានក្នុងសមរភូមិ។

អង្គការការីតាសកម្ពុជាបានប្រារព្ធពិធីនេះនៅក្នុងឆ្នាំ២០១៧ជាលក្ខណៈអន្តរសាសនាថ្នាក់ជាតិផង និងមានកិច្ចសហការយ៉ាងស្អិតរមួតពីរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងពិធីអធិដ្ឋានសម្រាប់ការយល់ដឹងប្រឆាំងនឹងការជួញដូរមនុស្ស នាឱកាសនោះក៏មានការអានសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ អធិដ្ឋានធម៌សកល អុជទៀនរៀបជារូបបេះដូង ជានិមិត្តរូបនៃសេចក្តីស្រឡាញ់ និងឧទ្ទិសដល់លើជនរងគ្រោះទាំងទាំងអ្នករស់ និងស្លាប់។ មានផ្តិតបាតដៃជាមួយពណ៌ផ្សេងៗ លើផ្ទាំងក្រណាត់សដោយបញ្ជាក់អត្ថន័យប្រឆាំងការជួញដូរមនុស្ស ។

អង្គការការីតាសកម្ពុជាជាអង្គការមួយនៃព្រះសហគមន៍កាតូលិក ដែលបានខិតខំយ៉ាងខ្លាំងក្នុងការតស៊ូមតិប្រឆាំងការជួញដូរមនុស្ស។ កន្លងទៅអង្គការការីតាស់កម្ពុជាបានសហការយ៉ាងជិតស្និទជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការអន្តរ-ជាតិជាដៃគូនៅក្រៅប្រទេសបានជួយពល-ករកម្ពុជាជាច្រើន ដែលរងគ្រោះដោយការលក់ដូរ និងកេងប្រវ័ញ្ចជាទាសភាព នៅក្រៅប្រទេស បានជាច្រើននាក់ផងដែរ។ ក្រៅពីនេះអង្គការការីតាសមានគម្រោងជាច្រើនទៀតដូចជា៖ គម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីអភិវឌ្ឍយុវជន កម្មវិធីអភិវឌ្ឍសហគមន៍ កម្មវិធីសុខភាព កម្មវិធីសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះ-ថ្នាក់ផ្សេងៗ៕

*ដោយ ឡុង សម្ផស្ស និង ដាលីស*

# សិក្ខាសាលាស្ដីអំពី "អាពាហ៍ពិពាហ៍"

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្រោមការដឹកនាំនិងយកចិត្តទុកដាក់ដោយលោកអភិបាលអូលីវីយេ រួមជាមួយគណៈកម្មការគ្រួសារទាំង៤ បានរៀបចំសិក្ខាសាលាស្ដីអំពី "អាពាហ៍ពិពាហ៍" ដើម្បីជួយឲ្យគ្រីស្ដបរិស័ទ និងគណៈដឹកនាំព្រះសហគមន៍យល់កាន់តែច្បាស់អំពីអត្ថន័យនៃអាពាហ៍ពិពាហ៍តាមរបៀបព្រះសហគមន៍កាតូលិក និងតាមប្រពៃណីខ្មែរ។

អង្គសិក្ខាសាលានេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២-៣ មីនា ២០១៨ ដោយមានវាគ្មិនមកពីក្រសួងធម្មការ និងសាសនា ឯកឧត្ដម សេង សុមុន្នី និងលោកអាចារ្យ អ៊ុក វាសនា ព្រមទាំងមានគ្រីស្ដបរិស័ទមកពីព្រះសហគមន៍នានាក្នុងភូមិភាគភ្នំពេញ រួមជាមួយតំណាងគ្រីស្ដបរិស័ទនៃព្រះសហគមន៍ភូមិភាគបាត់ដំបង និងកំពង់ចាម ចូលរួមផងដែរ។

នៅក្នុងកិច្ចស្វាគមន៍ លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ស្វាគមន៍ទៅកាន់សិក្ខាកាមទាំងអស់ថា ក្រុមគ្រួសារមិនគិតត្រឹមតែប្ដីប្រពន្ធដែលរៀបការហើយនោះទេ តែគិតចាប់ពីយុវជន យុវនារីដែលកំពុងរិះគិតអំពីអាពាហ៍ពិពាហ៍ ហើយសម្រាប់អ្នកដែលរៀបការរួចគឺគិតពីគ្រួសារដែលមានទុក្ខលំបាក គ្រួសារដែលមានសេចក្ដីសុខ គ្រួសារដែលមានបញ្ហា ហើយទៅជាការិយាល័យមួយយ៉ាងធំដើម្បីថែរក្សាជីវិតគ្រួសារ។ លោកបន្តថា ជីវិតគ្រួសារមានតាំងពីកុមាររហូតដល់ចាស់ជរា ជីវិតជាប្ដីប្រពន្ធ ជីវិតក្នុងការលែងលះគ្នា រួមទាំងជីវិតកុមារកំព្រាជាដើម ដែលទាក់ទងទៅនឹងគ្រួសារ។ លោកអភិបាលបញ្ជាក់ថាទោះបីបិទឆ្នាំគ្រួសារក៏ដោយ ប៉ុន្តែគណៈកម្មការគ្រួសារត្រូវតែបន្តជានិច្ច ព្រោះគ្រួសារជាជីវិតរបស់ព្រះសហគមន៍។

លោកអភិបាលបានបញ្ជាក់ទៀតថា នេះជាពេលវេលាមួយដើម្បីទទួលព័ត៌មាន និងចំណេះដឹងយ៉ាងច្បាស់អំពីអត្ថន័យនៃប្រពៃណីដែលយើងបានធ្វើ និងអត្ថន័យតាមប្រពៃណីដែលព្រះសហគមន៍បានបញ្ចូលទៅក្នុងអគ្គសញ្ញានីមួយៗ។

ក្នុងថ្ងៃដំបូងនេះដែរ លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា បានពន្យល់ដល់សិក្ខាកាមអំពីអត្ថន័យនៃអាពាហ៍ពិពាហ៍ និងប្រពៃណីតាមរបៀបព្រះសហគមន៍កាតូលិកផងដែរ។

នៅថ្ងៃបន្ទាប់វាគ្មិនដែលជា លោកអាចារ្យ អ៊ុក វាសនា បានពន្យល់អំពីអត្ថន័យនៃពាក្យ"អាពាហ៍ពិពាហ៍" និងប្រវត្តិអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ព្រមទាំងមានការអនុវត្តជាក់ស្ដែង។ រីឯលោកឯកឧត្ដម សេង សុមុន្នី ក៏បានអធិប្បាយអំពីច្បាប់នានានៅក្នុងប្រទេសកម្ពុជា ព្រមទាំងមានការបកស្រាយនូវចម្ងល់ផ្សេងៗរបស់សិក្ខាកាមផងដែរ។

លោកអភិបាលអូលីវីយេ នេះជាឱកាសមួយដើម្បីឲ្យយើងគិត និងយល់ថែមទៀតអំពីអាពាហ៍ពិពាហ៍តាមប្រពៃណីជាពិសេសសម្រាប់ព្រះសហគមន៍កាតូលិកដែលចូលនៅក្នុងជីវិតនៃប្រជាជនកម្ពុជា។ លោកថាអគ្គសញ្ញានៅក្នុងគ្រីស្ដសាសនាមិនសូវមានច្រើនប៉ុន្មានទេ គឺមានតែពាក្យសច្ចាវវាងប្ដី និងប្រពន្ធដែលមានឯកភាពរស់នៅជាមួយគ្នាអស់មួយជីវិត និងមានព្រះពរពីព្រះជាម្ចាស់ រួមជាមួយសញ្ញានៃចិញ្ចៀនដែលបង្ហាញថាភ្ជាប់ដោយភក្ដីភាព សេចក្ដីស្រឡាញ់អស់មួយជីវិត និងដោយព្រះជាម្ចាស់គង់នៅជាមួយអស់មួយជីវិតតែប៉ុណ្ណោះ។ លោកបន្ថែមថា នៅពេលយើងធ្វើអគ្គសញ្ញាអាពាហ៍ពីពាហ៍នៅទីនេះយើងបញ្ចូលតាមប្រពៃណីខ្មែរផងដែរ ដោយមានបង្វិលពពិល មានចងដៃ មានបាចផ្កា មានដារ មានទេវតាចុះមកកាត់សក់ មានលាងជើង និងសញ្ញាផ្សេងៗយ៉ាងច្រើនទៀតផងដែរ។

លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា បានមានប្រសាសន៍ថា សិក្ខាសាលានេះពិតជាមានអត្ថន័យ និងអត្ថប្រយោជន៍សម្រាប់គ្រីស្ដបរិស័ទ ក៏ដូចជាបូជាចារ្យផងដែរ ដើម្បីយល់ពីអត្ថន័យ និងប្រៃណីអាពាហ៍ពិពាហ៍ជាមួយគ្រីស្ដសាសនា និងតាមជំនឿរបស់យើងដែរជាគ្រីស្ដបរិស័ទ។ លោកបន្ថែមថា មុនពេលរៀបអាពាហ៍ពិពាហ៍ជាអគ្គសញ្ញាមួយ ហើយអគ្គសញ្ញានោះតាមទេវវិទ្យា និងតាមជំនឿរបស់យើង គឺ មានអត្ថន័យយ៉ាងជ្រៅក្នុងជីវិតរបស់គូស្រករ ហើយសិក្ខាសាលានេះ សង្ឃឹមថាបានជួយបញ្ជាក់នូវអត្ថន័យនៃអាពាហ៍ពិពាហ៍ដែលព្រះជាម្ចាស់ គឺព្រះយេស៊ូចូលរួមជាមួយយើងនៅក្នុងអាពាហ៍ពិពាហ៍ ក្នុងជីវិតប្ដីប្រពន្ធ និងកូន ព្រោះថាគ្រីស្ដបរិស័ទអត់មានច្បាប់លែងលះគ្នាទេ ហើយនេះជាឧទាហរណ៍ ដូច្នេះត្រូវរៀបចំខ្លួនមុននឹងចូលពិធីអាពាហ៍ពិពាហ៍។ លោកថានៅក្នុងព្រះសហគមន៍មានច្បាប់ជាច្រើនដែលចេញពីអត្ថន័យនៃអាពាហ៍ពិពាហ៍នេះ។

គួរបញ្ជាក់ផងដែរថា នេះជាលើកដំបូងហើយដែលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំសិក្ខាសាលា នៅក្នុងឆ្នាំគ្រួសាដែលមានរយៈពេលបីឆ្នាំ(២០១៧ដល់២០២០) ដើម្បីរិះគិតអំពីក្រុមគ្រួសារដោយយកចិត្តទុកដាក់គិតពិចារណាអំពីជីវិតនៃគ្រួសារ។ ព្រះសហគមន៍ភូមិភាគភ្នំពេញក៏បានបង្កើតឲ្យមានគណៈកម្មការនៅក្នុងឆ្នាំគ្រួសារនេះមានបួនគឺ គណៈកម្មការទីមួយដែលបានរៀបចំសិក្ខាសាលានេះ គណៈកម្មការទីពរសម្រាប់យុវជនដើម្បីរិះគិតពីជីវិតជាក្រុមគ្រួសារ គណៈកម្មការទីបីគឺសម្រាប់អគ្គសញ្ញាអាពាហ៍ពីពាហ៍ និងគណៈកម្មការទីបួនដែលសំខាន់បំផុតហើយនឹងបង្កើតជាការិយាល័យមួយទៀតគឺ សម្រាប់ថែរក្សាក្រុមគ្រួសារ។ លើពីនេះទៀតព្រះសហគមន៍ក៏លើកទឹកចិត្តឲ្យគ្រីស្ដបរិស័ទអធិដ្ឋានតាមរយៈក្រុមគ្រួសារដ៏វិសុទ្ធផងដែរ៕



ថតដោយ សុធីរិទ្ធ

## សម្តេចប៉ាបៈ សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់គឺធំហួសពីយើងអាចគិត

ជាថ្មីម្តងទៀតសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងបញ្ជាក់ជាថ្មីអំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះគ្រិស្តសាសនិក និងមនុស្សទាំងអស់ ។

ថ្លែងនៅក្នុងធម៌ទេសនា កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ នៅវិមានសន្តសិលា នៅក្នុងទីក្រុងរ៉ូម សម្តេចប៉ាប បានមានប្រសាសន៍ថា ទោះបីជាមានអ្នកណាធ្វើអំពើបាបប៉ុន្តែទ្រង់នៅតែសន្តោសប្រណី ប្រសិនបើអ្នកនោះ នៅមានសេចក្តីស្រលាញ់ នៅមានមនសិការ និងការទទួលខុសត្រូវចំពោះអំពើបាបទាំងនោះ។

សម្តេចប៉ាបក៏បានថ្លែងបញ្ជាក់គ្រិស្តបរិស័ទថា សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ គឺធំធេងជាអ្វី ដែលយើងអាចគិតបាន។ សេចក្តីស្រលាញ់នោះ គឺវាធំហួសអំពើបាប ទៅទៀតប្រសិនបើជាយើងទទួលស្គាល់ ហើយហ៊ានសារភាពអំពើទាំងនោះ ប្រកបដោយមនសិការត្រឹមត្រូវ។

សម្តេចប៉ាបក៏បានរំលឹកគ្រិស្តបរិស័ទទៀតថា នេះគឺជាសេចក្តីស្រលាញ់ដែលគ្មានព្រំដែន គ្មានដែនកំណត់ គ្មានឧបសគ្គ គ្មានការរារាំង ឲ្យតែយើងហ៊ានអះអាងហ៊ានទទួលស្គាល់កំហុស និងអំពើបាបទាំងឡាយណា ដោយមនសិការ ។

សម្តេចប៉ាបបានបញ្ជាក់ថា អំពើបាបគឺជាគម្លាតរវាងយើង និងព្រះជាម្ចាស់ ហើយកាលណា យើងធ្វើអំពើបាប នោះគឺយើងធ្វើឲ្យខ្លួនយើងនៅឆ្ងាយពីព្រះជាម្ចាស់ដោយខ្លួនយើង ប៉ុន្តែប្រសិនបើយើងទទួលស្គាល់នោះ គឺជារឿងមួយដែលគម្លាតនោះរួមមកវិញ ៕

## សម្តេចប៉ាបគ្រោងនឹងទៅទស្សនកិច្ចប្រទេសបីនៅតំបន់បាល់ទិច

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ត្រូវបានការិយាល័យព័ត៌មាននៃបុរីវ៉ាទីកង់ប្រកាសថា សម្តេចគ្រោងហនឹងអញ្ជើញទៅបំពេញទស្សនៈកិច្ចនៅប្រទេសយ៉ាងហោចណាស់បីនៅតំបន់បាល់ទិក នៅក្នុងពេលខាងមុខនេះ ។

បណ្តាញព័ត៌មានហ្សីណែត បានរាយការណ៍ថា តាមការគ្រោងទុកបុរីវ៉ាទីកង់នឹងរៀបចំដំណើរ ទស្សនកិច្ចនោះ នៅក្នុងវង្វង់ខែកញ្ញា។ ហើយប្រទេសដែលសម្តេចប៉ាបគ្រោងនឹងអញ្ជើញទៅ ទស្សនៈកិច្ចនោះ គឺមានប្រទេសលីទុយអានីឡាតវៀ និងអេស្តូនី ។

ប្រភពដដែលបានបន្តថា ដំណើររបស់សម្តេចប៉ាបទៅកាន់ប្រទេសទាំងបីនេះ គឺជាដំណើរ ទស្សនកិច្ចផ្លូវការ ហើយសម្តេចប៉ាបគ្រោងនឹងចេញដំណើរពីថ្ងៃទី២២ ដល់ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ដោយគ្រោងទៅទស្សនកិច្ច នៅទីក្រុងចំនួន ៥ នៅប្រទេសទាំងបី ។

សម្តេចប៉ាបគ្រោងនឹងទៅទស្សនកិច្ចនៅទីក្រុង វិលនីស និងកូណាស នៅប្រទេសលីទុយអានី រួចបន្តទៅ ទីក្រុងរីហ្គា និងអាកឡូណា នៅប្រទេសឡាតវៀ និងទីក្រុង តាលីន នៅប្រទេសអេស្តូនី ៕

## សម្តេចប៉ាបៈ ស្ត្រី គឺជាពិភពដ៏ស្រស់ស្អាតនិងសុខសាន្តនៅលើពិភពលោក

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ នៅពេលថ្មីៗនេះបានវាយតម្លៃខ្ពស់អំពីគុណតម្លៃនៃស្ត្រី ហើយបានចាត់ទុក ស្ត្រី គឺជា ពិភពមួយដ៏ស្រស់ស្អាត និងសុខសាន្តនៅលើពិភពលោកយើងនេះ។

ហ្សីណែត បានអះអាងថា នេះគឺជាសំដីរបស់សម្តេចប៉ាប ដែលដកស្រង់ចេញពីវីដេអូមួយ ដែលសម្តេចនិយាយអំពីតម្លៃនៃព្រះសហគមន៍កាតូលិក និងពិភពនៃស្ត្រី។

ប្រភពដដែលបានអះអាងថា វីដេអូដែលបានផ្សព្វផ្សាយកាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ នៅចំថ្ងៃសិទ្ធិនារីអន្តរជាតិ សម្តេចប៉ាបបានមានប្រសាសន៍ថា ស្ត្រីគឺជាដៃគូដ៏មានតម្លៃរបស់ព្រះសហគមន៍ និងពិភពលោក។

សម្តេចប៉ាបក៏បានថ្លែងទៀតថា ព្រះសហគមន៍កាតូលិក និងព្រះវិហារកាតូលិកទាំងឡាយ គឺស្រស់ស្អាតដូចជា នារីដូច្នេះដែរ។ ព្រះវិហារគឺជាស្ត្រីម្នាក់ ហើយ ស្ត្រីនោះ គឺជាមាតា និងជាភរិយាដ៏ស្រស់ស្អាត។

សម្តេចប៉ាបបានថ្លែងបញ្ជាក់ថា ប្រសិនបើគ្មានស្ត្រី ពិភពលោក និងមិនស្រស់ស្អាត ហើយក៏នឹងមិនមានសុភមង្គលដែរ ៕

## សម្តេចប៉ាបលើកទឹកចិត្តដល់ក្រុមគិលានុបដ្ឋាយិការអ៊ីតាលី

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៨ បានជួបជាមួយនឹងក្រុមគិលានុបដ្ឋាយិកាអ៊ីតាលី ហើយក៏បានផ្តាំផ្ញើរមួយចំនួន ដើម្បីឲ្យពួកគេអាចបំពេញកិច្ចការដើម្បី សង្គមប្រកបដោយសេចក្តីស្រលាញ់ ។

បណ្តាញព័ត៌មានហ្សីណែត បានរាយការណ៍ថា ជំនួបនោះ គឺធំដោយមានសមាជិករហូតដល់ទៅ ៦.៥០០ នាក់ ដោយពួកគេគឺសុទ្ធតែជា គិលានុបដ្ឋាយិការ ដែលជាសមាជិកនៃសហព័ន្ធមហាវិទ្យាល័យវិជ្ជាជីវគិលានុបដ្ឋាយិការ ដោយពួកគេ គឺជាតំណាងនៃសមាជិកសរុបប្រមាណជា ៤៥០.០០០ នាក់ ។

ប្រភពដដែលបានរាយការណ៍ថា ជំនួបនេះ គឺបានរៀបចំឡើងនៅវិមានយូហានទី៥ នៅបុរីវ៉ាទីកង់ ហើយនៅក្នុងឱកាសនោះ សម្តេចប៉ាបក៏បានរំលឹកពួកគេនូវចំណុចដ៏សំខាន់មួយចំនួន ដែលរួមមានដូចជាក្រមសីលធម៌ កិត្តិនាម ផ្សព្វផ្សាយពីសុខភាព បង្កាសុខភាព កាត់បន្ថយសោកនាដកម្ម ផ្សេងៗ ។

សម្តេចប៉ាបបានហៅគិលានុបដ្ឋាយិការ ថា គឺជាអ្នកជំនាញប្រកដោយ តម្លៃនៃមនុស្សជាតិ ហើយបានប្រកាសទទួលស្គាល់ថា កិច្ចការនេះ គឺជាកិច្ចការ ដ៏លំបាក ហើយក៏បានស្នើសុំឲ្យ អ្នកជំងឺទាំងអស់ព្យាយាមអត់ធ្មត់ ៕

## សម្តេចប៉ាបជំរុញឲ្យអ្នកដែលមានជំនឿទាំងអស់រស់នៅក្នុងសិរីរុងរឿងរបស់ព្រះជាម្ចាស់

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៨ បានជំរុញឲ្យមនុស្សជាពិសេសគ្រិស្តបរិស័ទទាំងអស់រិះគិតជាថ្មីអំពីព្រះជាម្ចាស់ ដោយថ្លែងថា ព្រះជាម្ចាស់ តែងតែនៅជាមួយយើង ហើយជួយយើងឲ្យរស់នៅក្នុងជីវិតមួយ ដែលអាចនឹងសិរីរុងរឿងដូចជា ព្រះ អង្គ។

សម្តេចប៉ាបបញ្ជាក់ថា "សេចក្តីរុងរឿងរបស់ព្រះជាម្ចាស់ គឺជាច់ខាតមិនមែនជាជីវិតមួយ ដែលបរិបូណ៍ទៅដោយទ្រព្យសម្បត្តិ និងផលប្រយោជន៍នោះទេ ប៉ុន្តែជា សិរីរុងរឿង និងក្តីស្រលាញ់ដ៏សាមញ្ញរបស់ព្រះជាម្ចាស់"។

បណ្តាញព័ត៌មានហ្សីណែត បានរាយការណ៍ថា នេះ គឺជា ការថ្លែងរបស់សម្តេចប៉ាប ទៅកាន់គ្រិស្តបរិស័ទ ប្រមាណជា ២០.០០០នាក់ នៅទីលានសន្តសិលា។

សម្តេចប៉ាបបានរំលឹកគ្រិស្តបរិស័ទ ឲ្យយកចិត្តទុកដាក់ចំពោះ អ្វីដែល ជា ក្តីស្រលាញ់ អ្វីដែលមិនមែនជាអំពើហិង្សា ប៉ុន្តែជាសកម្មភាពដ៏រឹងមាំ ដើម្បីខ្លួនយើងនិងអ្នកដទៃអាចរស់នៅជាមួយគ្នា ដោយស្ងប់ស្ងាត់ និងមានសុភមង្គល។

កាលពីសម័យបុរាណ គ្រិស្តបរិស័ទ ខ្លះចង់ឲ្យព្រះយេស៊ូ ប្រើឥទ្ធិពល និងថាមពលអរូបិយ ដើម្បីប្រែក្លាយសេចក្តីលោភលន់ ការចង់បាន ការគេចចេញពីក្តីស្លាប់ ប៉ុន្តែទ្រង់ថា នោះគឺជាសេចក្តីពិត ដែលមនុស្សគួរតែធ្វើ គួរតែរៀនស្វែងរកតាមគំរូព្រះជាម្ចាស់ ។ នេះបើតាមប្រសាសន៍របស់សម្តេចប៉ាប ។

សម្តេចប៉ាបបានថ្លែងបន្តទៀតថា យើងគ្រប់គ្នា អាចនឹងរស់នៅក្នុងពន្លឺនៃសិរីរុងរឿង ជាមួយនឹងទ្រង់បានគ្រប់ពេល ប៉ុន្តែគឺត្រូវតែ មានសេចក្តីស្រលាញ់ និងការលះបង់ ដូចដែល ព្រះយេស៊ូ ព្រះអង្គធ្លាប់បានបូជាដើម្បីសេចក្តីស្រលាញ់ កន្លងមក។

សម្តេចប៉ាបបានថ្លែងថា យើងជាគ្រិស្តបរិស័ទ គឺគួរតែអាចរស់ពោរពេញដោយក្តីស្រលាញ់ ដោយខ្លួនយើង និងទទួលបានផលប្រយោជន៍ផ្សេងៗ ដោយការខិតខំប្រឹងប្រែងរបស់យើង នៅក្រោមសិរីរុងរឿងនៃ ព្រះជាម្ចាស់ ៕

# "ចូរនាំគ្នាមក ពួកយើងវិលទៅរកព្រះអម្ចាស់វិញ" អភិបូជាអធិដ្ឋាន២៤ម៉ោងនៅភ្នំពេញថ្មី ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨

*អត្ថបទទី១៖ ហស ៦,១-៦*
*ដំណឹងល្អ៖ លក ១៨,៩-១៤*

បងប្អូនជាទីស្រឡាញ់!

ចូរនាំគ្នាមក ពួកយើងវិលទៅរកព្រះអម្ចាស់វិញ យើងអធិដ្ឋាន២៤ម៉ោង ដើម្បីនឹកឃើញដល់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ដែលបានប្រទានជីវិតឲ្យយើង ដែលបានប្រទានឲ្យយើងរស់នៅក្នុងសេចក្តីសុខសាន្តព្រះជាម្ចាស់ដែលបានធ្វើដំណើរជាមួយយើង។ ខ្ញុំជឿថាប៉ុន្មានឆ្នាំកន្លងមកដែលសម្តេចប៉ាប បានបង្កើតឲ្យមានការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ ជាពេលវេលាមួយយ៉ាងពិសេសសម្រាប់ព្រះសហគមន៍ទាំងមូល ដើម្បីរួមគ្នាទៅជាអង្គតែមួយទូលអង្វរទៅព្រះជាម្ចាស់ ដើម្បីឲ្យយើងយល់ថាពិតមែនជីវិតរបស់យើងជាបរិស័ទរបស់ព្រះគ្រីស្ត យើងភ្ជាប់ជាមួយព្រះយេស៊ូជាអម្ចាស់ ដែលជាជីវិតរបស់យើង។ យើងមិនមែនអធិដ្ឋានតែតាមកន្លែងរបស់យើងរៀងៗខ្លួនពីរបីម៉ោងទេ សំខាន់គឺយើងទាំងអស់ជាព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ យើងមូលអារម្មណ៍២៤ម៉ោង។ យើងមិនអធិដ្ឋាន២៤ម៉ោងនៅកន្លែងណាមួយ ប៉ុន្តែយើងដឹងថាយើងមានគ្រីស្តបរិស័ទ យើងមានបងប្អូនយើងដែលកំពុងអធិដ្ឋាន នៅក្នុងគោលដៅតែមួយត្រលប់មកវិញទៅរកព្រះអម្ចាស់ ក្នុងគោលដៅតែមួយណែនាំឲ្យពិភពលោករបស់យើងមានសេចក្តីសុខ។



យើងមានផ្លែមួយពីការអធិដ្ឋានរបស់យើង ព្រះជាម្ចាស់បានណែនាំលោកឱលណាត្រាំមឲ្យជួបជាមួយមេដឹកនាំនៃប្រទេសកូរ៉េខាងជើង និងមេដឹកនាំនៃប្រទេសកូរ៉េខាងត្បូងដែលនេះជាជំនួបលើកទីមួយនៃប្រវត្តិសាស្ត្ររបស់ពិភពលោក។ យើងត្រូវតែជឿលើព្រះជាម្ចាស់ ព្រោះហេតុការណ៍កើតឡើងនៅពេលគ្រីស្តបរិស័ទក្នុងពិភពលោកទាំងមូលកំពុងអធិដ្ឋានសម្រាប់សេចក្តីសុខក្នុងពិភពលោក។ សម្រាប់យើងនៅក្នុងទ្វីបអាស៊ីនេះជាសញ្ញាមួយពិសេស ហើយក៏ណែនាំឲ្យយើងកំពុងភ័យខ្លាចដែរ ព្រោះថាអ្វីដែលកំពុងកើតឡើងរវាងប្រទេសកូរ៉េទាំងពីរ មានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងតំបន់របស់យើង និងពិភពលោកទាំងមូល។ នេះជាជំហានមួយ ដែលបង្ហាញអំពីឆន្ទៈចង់បង្កើតសេចក្តីសុខសាន្ត ដោយជឿថាជាព្រះជាម្ចាស់ ដែលកំពុងមានស្នាព្រះហស្តនៅក្នុងដួងចិត្តរបស់អ្នកដឹកនាំ។

ការអធិដ្ឋានរបស់យើងមានផ្លែ លុះត្រាតែយើងធ្វើតាមអ្វីដែលព្រះយេស៊ូបានបង្ហាញនៅក្នុងអត្ថបទគម្ពីរដំណឹងល្អថ្ងៃនេះ ប្រសិនបើយើងជាគណៈផារីស៊ីដែលអធិដ្ឋានដោយបង្ហាញឲ្យគេឃើញ ដោយនិយាយទៅព្រះជាម្ចាស់ថាខ្ញុំជាមនុស្សល្អ ខ្ញុំមិនមែនជាមនុស្សអាក្រក់ដូចគេ ខ្ញុំជាមនុស្សដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ជានិច្ចដូចពាក្យទូលអង្វររបស់គណៈផារីស៊ីដែលទូលថា "បពិត្រ ព្រះជាម្ចាស់ទូលបង្គំសូមអរព្រះគុណព្រះអង្គ ព្រោះទូលបង្គំមិនដូចជនឯទៀតៗទេ អ្នកទាំងនោះសុទ្ធតែជាចោរជាមនុស្សទុច្ចរិត ជាមនុស្សប្រព្រឹត្តអំពើផិតក្បត់ ហើយទូលបង្គំក៏មិនដូចអ្នកទារពន្ធនេះដែរ ទូលបង្គំតមអាហារពីរដងក្នុងមួយអាទិត្យ ហើយទូលបង្គំថ្វាយរបស់អ្វីៗទាំងអស់ដែលទូលបង្គំរកបាន មួយភាគដប់ដល់ព្រះអង្គ" នេះអាចណែនាំឲ្យយើងមានពេលដើម្បីនឹកឃើញថាយើងជាមនុស្សយ៉ាងណា? ព្រះយេស៊ូថ្ងៃនេះ បានឲ្យគំរូមួយយ៉ាងពិសេសគឺអ្នកទារពន្ធដែលបានទូលអង្វរថា ឱព្រះជាម្ចាស់អើយ! សូមអាណិតទូលបង្គំដែលជាមនុស្សបាបផង។ ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធនេះឲ្យបានសុចរិត ហើយគាត់ត្រឡប់ទៅផ្ទះវិញ រីឯបុរសខាងគណៈផារីស៊ីមិនបានសុចរិតទេ។

នៅក្នុង២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ ឲ្យយើងយកពេលដើម្បីត្រលប់ទៅរកព្រះជាម្ចាស់វិញ ដោយមើលឃើញជីវិតរបស់យើងផ្ទាល់។ ជាមូលហេតុនៅក្នុងយប់នេះនឹងថ្ងៃស្អែក ជាពេលវេលាមួយដើម្បីទទួលអត្តសញ្ញាលើកលែងទោស ដោយទទួលស្គាល់ថាយើងមិនមែនជាមនុស្សអស្ចារ្យ ប៉ុន្តែយើងជាមនុស្សដែលពោរពេញដោយអំពើបាប ហើយបយើងទទួលស្គាល់អំពើបាបរបស់យើង ដោយទូលអង្វរថា ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង។ នេះជាការអធិដ្ឋានយ៉ាងពិតៗ ដែលចេញពីដួងចិត្តរបស់យើង និងណែនាំឲ្យជីវិតរបស់យើងបន្តិចម្តងៗ អាចជាប់ជាមួយព្រះជាម្ចាស់ថែមទៀត ដើម្បីឲ្យស្នាព្រះហស្តរបស់ព្រះអង្គអាចទៅគ្រប់ទីកន្លែងតាមរយៈជីវិតរបស់យើង។ ព្រះជាម្ចាស់ស្តាប់ពាក្យទូលអង្វររបស់យើង ព្រះជាម្ចាស់ស្តាប់ពាក្យអធិដ្ឋានរបស់យើង ដែលបានអធិដ្ឋានអស់ពីដួងចិត្តដោយសូត្រថា សូមព្រះអង្គជួយខ្ញុំផងឲ្យខ្ញុំទៅជាមនុស្សថ្មី សូមព្រះអង្គជួយខ្ញុំផងដោយសារខ្ញុំធ្លាប់ធ្វើអំពើខុសដើរឆ្ងាយពីព្រះជាម្ចាស់ សូមព្រះអង្គជួយឲ្យខ្ញុំទៅជាមនុស្សថ្មីដែលជាប់ជាមួយព្រះហឫទ័យរបស់ព្រះអង្គ ដើម្បីឲ្យព្រះអង្គទទួលស្គាល់នឹងណែនាំឲ្យខ្ញុំធ្វើជាមនុស្សសុចរិកយ៉ាងពិតប្រាកដ។

ការអធិដ្ឋានរបស់យើងមានឥទ្ធិពលសម្រាប់ជីវិតរបស់យើង នៅពេលយើងធ្វើតាមព្រះយេស៊ូ ដាក់ខ្លួនដោយទទួលស្គាល់អំពើបាបរបស់យើង ដើម្បីឲ្យយើងធ្វើជាមនុស្សថ្មី។ ការអធិដ្ឋានរបស់យើងមានឥទ្ធិពល នៅពេលយើងអធិដ្ឋានមិនគិតតែពីយើងផ្ទាល់ តែយើងអធិដ្ឋានយ៉ាងទូលំទូលាយដល់បងប្អូនដែលកំពុងស្អប់យើង ដល់បងប្អូនដែលកំពុងមានទុក្ខលំបាក ដល់មនុស្សដែលយើងមិនស្គាល់ ដោយជឿថាការអធិដ្ឋានរបស់យើងជាទំនាក់ទំនងយ៉ាងពិសេសដែលយើងបង្កើត ជាមួយមនុស្សដែលនៅឆ្ងាយពីយើង ជាមួយមនុស្សដែលកំពុងមានទុក្ខលំបាក ជាមួយមនុស្សដែលកំពុងស្អប់យើង។ យើងមើលអ្វីៗទាំងអស់ដោយដឹងថា ការអធិដ្ឋានរបស់យើងពីភូមិភាគភ្នំពេញយប់នេះ ទៅដល់គ្រប់ទីកន្លែងនៃពិភពលោកទាំងមូល និងអាចមានឥទ្ធិពលលុះត្រាតែយើងទទួលស្គាល់ថា យើងជាគ្រីស្តបរិស័ទដែលដាក់ខ្លួនដែលជាមនុស្សមានបាប ប៉ុន្តែយើងអធិដ្ឋានអស់ពីដួងចិត្តដោយសារយើងស្រឡាញ់ព្រះជាម្ចាស់ ហើយយើងជឿថា ព្រះជាម្ចាស់ជួយយើងដើម្បីឲ្យយើងទៅជាមនុស្សថ្មី។

ឆ្នាំមុននៅភូមិសុខសាន្ត មានមនុស្សគរម្នាក់ដែលនិយាយបាន ហើយពីរថ្ងៃមុនប្អូនរបស់គាត់ដែលគរដូចគ្នាក៏អាចនិយាយបានដែរ នេះជាការអស្ចារ្យដែលបានកើតឡើងដោយសារយើងបានអធិដ្ឋានសម្រាប់គាត់។ ការអធិដ្ឋានរបស់យើង មានឥទ្ធិពលយ៉ាងពិតប្រាកដមែន ដោយសារព្រះជាម្ចាស់ស្តាប់យើងជានិច្ច ប៉ុន្តែតើយើងចេះបើកភ្នែកឬអត់? ចេះទទួលស្គាល់ថាសញ្ញានេះ ថាជាសញ្ញាដែលព្រះជាម្ចាស់ដែលកំពុងធ្វើការនៅក្នុងជីវិតរបស់យើងឬទេ? យប់នេះឲ្យយើងយកពេល ដោយអធិដ្ឋានដើម្បីត្រលប់ទៅរកព្រះជាម្ចាស់វិញ។ ចំពោះយើងផ្ទាល់ យើងអធិដ្ឋានយ៉ាងទូលំទូលាយសម្រាប់សេចក្តីសុខនៅក្នុងពិភពលោកទាំងមូល អធិដ្ឋានសម្រាប់ក្រុមគ្រួសាររៀងៗខ្លួនដើម្បីឲ្យគ្រួសាររបស់យើងរកឃើញសេចក្តីសុខសាន្តនិងសុភមង្គលយ៉ាងពិតប្រាកដ នឹងណែនាំដើម្បីឲ្យយើងរួមគ្នាជាអង្គតែមួយ ដោយដឹងថាយើងជាព្រះសហគមន៍តែមួយ យើងជាមហាគ្រួសារនៃអង្គព្រះគ្រីស្ត។ ខ្ញុំចង់ឲ្យយប់នេះនិងថ្ងៃស្អែក យើងធ្វើបទពិសោធន៍មួយយ៉ាងពិសេសនៅក្នុងភូមិភាគភ្នំពេញទាំងមូល ដោយយល់ថាយើងជាគ្រួសារតែមួយ កំពុងអធិដ្ឋានសម្រាប់គោលដៅតែមួយ យើងជាគ្រួសារមួយ ដែលកំពុងចាប់ដៃគ្នាដើម្បីអធិដ្ឋានរួមគ្នាកសាងព្រះសហគមន៍របស់យើង កសាងសង្គមរបស់យើងដែរ។ យើងអធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់ ដើម្បីឲ្យយើងត្រលប់ទៅរកព្រះជាម្ចាស់វិញ ទៅជាមនុស្សថ្មីដែលបង្កើតសេចក្តីសុខដល់មនុស្សនៅជុំវិញយើង និងដល់មនុស្សនៅក្នុងពិភពលោកទាំងមូល ដោយសារពាក្យអធិដ្ឋានរបស់យើង ដោយជឿថាព្រះជាម្ចាស់ស្តាប់លុះត្រាតែយើងនិយាយថា ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង។ អាម៉ែន៕

សូមសំដែងអបអរសាទរចំពោះលោក
អភិបាល **អេនរីគេ ហ្វីការរេដូ**
ជាអភិបាលព្រះសហគមន៍ភូមិភាគ
បាត់ដំបង ដែលបានទទួលស្គាល់ជា លោក
អភិបាលនៃរទេះជនពិការ ដែល
បានធ្វើការលើកិច្ចការមនុស្ស
ធម៌ជាមួយជនរងគ្រោះ ដោយសារ
គ្រាប់មីននៅអាស៊ីអាគ្នេយ៍។ លោកអភិបាល
បានទទួលបណ្ឌិតកិត្តិយសពីសកលវិទ្យាល័យ
សន្តល្វីស ប្រទេសអេស្ប៉ាញ។
សូមព្រះជាម្ចាស់ប្រទានព្រះពរដល់លោក
អស់កល្បជានិច្ច !



Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវីរីតាស់អាស៊ីខេមរភាសា

## សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវីរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com, www.catholiccambodia.org

- លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

✤ **តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវីរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com